# LA MINORITE CAMBODGIENNE DE COCHINCHINE

( Extrait du Bulletin de la
Société des Etudes Indochinoises )
Tome XXI 1er Semestre 1946

Par LOUIS MALLERET

# ជនជាតិភាគតិចខ្មែរ នៅ ដែនកូសាំងស៊ីន

ដោយ ល្វី ម៉ាល្លឺរ៉េ

ប្រែសំរួលដោយ អេង~សេរីបុត្រ

ការផ្សាយរបស់សារពត៌មាន«អង្គរបុរី»
រក្សាសិទ្ធិគ្រប់យ៉ាង

(គ.ស.២០០៤ - ព.ស.២៥៤៨)

បើប្រសិនជាខ្ញុំបានជ្រើសរើសយកមកនិយាយពីជនជាតិខ្មែរនៅដែនដីកូសាំងស៊ីននោះ ក៏ព្រោះតែខ្ញុំយល់ឃើញថាជាការមានសារៈប្រយោជន៍ខ្លាំងណាស់ក្នុងការឆ្លើយតបទៅនឹងសិទ្ធិរបស់ជនជាតិភាគតិចមួយចំនួនដ៏សំខាន់ នេះបើគេមិនគិតទៅលើលក្ខ័ណនៃប្រវត្តិសាស្ត្រទេ ។

ជាការពិតណាស់ ដែនដីកូសាំងស៊ីនមិនអាចយកទៅប្រៀបធៀប ជាមួយនឹងប្រជាជនគ្រប់ជាតិសាសន៍ ដែលរស់នៅតាមតំបន់ផ្នែកខាងលើនៃដែនដីតុងកឹងនៅតាមព្រំប្រទល់ដែនលាវ ឬនៅតាមដែនដីខ្ពង់រាបនៃភូមិភាគកណ្តាលនៃឥណ្ឌូចិន ដែលទាំងអស់គ្នាយល់ស្របឲ្យឈ្មោះថា ជាដែនដីរបស់ពពួកហិណ្ឌូនិងពួកម៉យនោះទេ ។ តែនៅពេលនេះ គេបានកត់សម្គាល់ឃើញនៅលើដែនដីតាមមាត់ទន្លេមេគង្គ នូវវត្តមាននៃជនជាតិភាគតិចជាច្រើន ដែលរស់នៅជួនកាលណែនណាន់តាន់តាប់លើគ្នា ជួនកាលរស់នៅឯណោះខ្លះឯណោះខ្លះ ដាច់ៗពីគ្នា ហើយមានកិរិតវប្បធម៌ឬចំណង់ចំណូលចិត្ត ដែលបានផ្តល់ចែកឲ្យនូវលក្ខណៈសម្គាល់ធាតុដើមរបស់គេ ។ បើសិនជាច្បាប់ថ្មីបានផ្តល់ឲ្យពិភពលោកនូវសន្ទុះថ្មីក្នុងការគោរពដល់បុគ្គលិកលក្ខណៈពិសេសនៃជនជាតិដែលទន់ខ្សោយនោះ ខ្ញុំនឹងរៀបរាប់នៅពេលនេះ ដើម្បីជាជំនួយដល់ស្មារតី នៃជនជាតិតូចតាចតិចតួចខ្លះ ដូចជា ៖ ម៉យ, ស្មៀង, ម៉ា ឬភ្នង ដែលរស់នៅតាមជំរាលភ្នំតាមព្រំដែនភាគខាងជើង និងទិសខាងកើតនៃដែនដីកូសាំងស៊ីន ។ ម្យ៉ាងទៀតសហគមនៃជាតិសាសន៍ទាំងនោះ ជួនកាលរស់នៅផ្សងព្រេង ដោយឥតមានលំនៅពិតប្រាកដប្រជា ( tantôt errantes, tantôt sédentaires ) ជួនរស់នៅនឹងមួយកន្លែង... ក៏ពួកនោះអាចជាតំណាងជនជាតិដែលបានកាន់កាប់ទឹកដីត្រង់នោះមុនគេដែរ ដោយមានចំនួនភាគច្រើនរហូតដល់រយៈពេលយូរអន្លង់ក្រោយៗមកបានរាតត្បាតពេញលើដីត្រង់ពាមលយចូលក្នុងសមុទ្រ ( le Delta ) ។ លក្ខណៈពិសេសរបស់ពួកគេ ក៏កាន់តែចុះអន់ថយនៅចំពោះមុខជនជាតិយួនដ៏ច្រើនក្រៃលែង ក៏ដូចជាការលោយបាត់បង់អស់នូវស្ទួលនៃជនជាតិចាម ដែលបានកកើតមុនគេនៅត្រង់ភូមិភាគតែនិញដូច្នោះដែរ ។ ក៏ប៉ុន្តែនៅក្នុងខេត្តមាត់ជ្រូក ( ចូវដុក ) គេប្រទះឃើញជនជាតិជ្វា និងជនជាតិចាមនៅតែរក្សាជំនឿរបស់គេទៅលើគម្ពីរកូរ៉ង់ ( Corant ) ហើយដែលលោក Marcel NER បានចង្អុលបញ្ជាក់យ៉ាងត្រឹមត្រូវ នៅក្នុងអត្ថបទរបស់លោកចុះផ្សាយក្នុងព្រឹត្តិប័ត្រសាលាបារាំងនៅចុងបូព៌ា ( Bulletin de l'Ecole Française d'Extrême Orient ) ។

ក្រៅពីក្រុមទាំងឡាយដែលនៅជាប់លាប់ គេគោងរៀបរាប់ផងដែរនូវប្រជាជនអន្តោប្រវេសន៍ ដូចជាសហគមនៃពួកអ្នកកាន់សាសនាមហាម៉ាត់នៅទីក្រុងព្រៃ

នគរ និងចើឡឹង ( Saigon-Cholon ) ដែលនៅទីនោះពួកគេបានកសាងព្រះវិហារពីរ (2 mosquées)ព្រមទាំងនិគមជនហិណ្ឌូ ( ពួកកាន់សាសនាព្រាហ្មណ៍ ) និងពួក Sikhsដោយមានវត្តមានផ្នែកវប្បធម៌របស់គេ គឺព្រះវិ ហារមួយកន្លែងជាទីសក្ការៈបូជា (sanctuaires) ចំនួន៦កន្លែង ដែលមានបួនកន្លែងជាវិហារ ព្រាហ្មញ្ញសាសនា ។ ក្រុមមួយដ៏សំខាន់ទៀត ព្រោះពួកគេកាន់កាប់ និងធ្វើសកម្មក្នុងវិស័យ សេដ្ឋកិច្ចនៅលើដែនដីកូសាំងស៊ីនទាំងមូល នោះ គឺក្រុមចិន ដែលមានដើមកំណើតចេញពីហៃណាម, ក្វាងទុង ឬពីហ្វុកគៀន ហើយរស់នៅប្រមូលផ្តុំគ្នាជាសហគមដោយមានការចាត់ចែងយ៉ាងត្រឹមត្រូវល្អណាស់ គឺពួកចិនកង់តុង ពួកចិនអាកាស (Akas), ពួកចិនទ្រីវចូវ, ពួកចិនហ្វុកគៀន និងពួកចិនហៃណាម ។ គេគួរតែរាប់បញ្ចូលទៅក្នុងក្រុមចិនផងដែរ នូវកូនចៅកាត់ ចិន-យួន ( métis sino-annamites ) ដែលមានចំនួនតិចតួចស្តួចស្តើងណាស់ តែក៏មានចំនួនច្រើនបង្គួរដែរនៅទីក្រុងចើឡឹង, មីថរ និងសុកត្រាំង ព្រមទាំងនៅតាមឆ្នេរឈូងសមុទ្រសៀម គឺតាំងពីហាទៀងរហូតដល់ទឹកខ្មៅ (កាម៉ៅ ) ។

★ សហគមខ្មែរនៅកូសាំងស៊ីនមានចំនួនទាំងអស់ ប្រមាណ៥៥០,០០០នាក់ ក្នុងចំនួនប្រជាជនសរុប៤,៨០០,០០០នាក់ ។ បើគ្រាន់តែគេក្រឡេកមើលភ្លាម គេសង្កេតឃើញថា សមាមាត្រនេះហាក់ដូចជានៅខ្សោយណាស់ ព្រោះថាជាការពិតណាស់ទៅហើយ ដែលថាកំណើតរបស់ប្រជាជនយួន ដែលនៅពេញពាសក្នុងជ្រោយឥណ្ឌូចិនទាំងមូល មានសភាពកើនឡើងជាលំដាប់ ។ មិនតែប៉ុណ្ណោះសោត ការធ្វើអន្តោប្រវេសន៍សំដៅទៅទិសខាងត្បូងនៃជាតិសាសន៍យួន គួរកត់សម្គាល់ថាជាព្រឹត្តិហេតុប្រវត្តិសាស្ត្រមួយដ៏ថ្មីថ្មោងសោះ ។ គេមិនដឹងថា តើត្រូវរកមធ្យោបាយបែបណាឲ្យបានយុត្តិធម៌ខ្លះផង ក្នុងការបន្ថយល្បឿនហូរចូលនៃជាតិសាសន៍មកពីខាងជើងនេះ ។ តែគេតោងចាត់ទុកថា ជាសិទ្ធិរបស់ជនជាតិភាគតិចផងដែរ ជាពិសេសជនជាតិទាំងនោះ ជាតំណាងឲ្យជនជាតិសាសន៍មួយ ដែលបែកចេញពីគេដទៃទៀត ហើយដែលគេត្រូវតែតាមពិនិត្យអង្កេតមើលឥតឈប់ឈរ ចាប់តាំងពីសតវត្សដំបូងៗ រហូតមកដល់ពេលសព្វថ្ងៃនេះ ។

ប្រជាពលរដ្ឋខ្មែរ គេជួបប្រទះជាពិសេសនៅត្រង់ជ្រោយដីទន្លេធំនិងទន្លេបាសាក់ ។ ក្នុងខេត្តត្រាវិញនាឆ្នាំ១៩៣៧ មានប្រជាជនខ្មែរទាំងអស់៨២,០០០នាក់រស់នៅយ៉ាងកកកុញ ហើយដែលយួនមាន១៥៦,០០០នាក់ ។ នៅខេត្តសុកត្រាំង សមាមាត្ររវាងជាតិសាសន៍ទាំងពីរមាន ÷ ៥០,០០០នាក់ទល់និង១០៧,០០០នាក់ ។ នៅខេត្តបាក់លីវ ប្រជាពលរដ្ឋខ្មែរមានចំនួនតែមួយភាគប្រាំមួយ (១/៦)នៃប្រជាជនយួន ។ ឯនៅក្នុងខេត្តកឹងថើវិញ មានតែចំនួនមួយភាគដប់(១/១០)ប៉ុណ្ណោះ ។

ក៏ប៉ុន្តែនៅខេត្តរ៉ាច់យ៉ា (ក្រមួនស) ចំនួនប្រជាពលរដ្ឋខ្មែរក្រោមបានកើនឡើងវិញស្មើនឹងមួយភាគបី (១/៣) ពោលគឺមានចំនួន៦៥,០០០នាក់ទល់នឹង១៩២,០០០នាក់



ព្រះវិហារដ៏ស្រស់បំព្រងខាងលើនេះ គឺព្រះវិហារវត្ត « សេរីសុខុមសង្គមមានជ័យ » ខេត្តឃ្លាំង ។ ព្រះវិហារស្រដៀងគ្នានេះ មានចំនួនទាំងអស់ជាងប្រាំរយស្ថិតនៅទូទាំងដែនដីកម្ពុជាក្រោមរបស់យើង ។ ក្រឡេកឃើញវត្តធ្វើឲ្យយើងស្រក់ទឹកភ្នែកស្រណោះដល់ទឹកដីដូនតាដែលបាត់បង់ទៅ ។ Photo: Thach Xé

នៅខេត្តហាទៀងដែលជាខេត្តដ៏តូចមានប្រជាជននៅតិចនៅឡើយនេះ ចំនួនជនជាតិទាំងពីរមានចំនួនប្រហាក់ប្រហែលគ្នា ។ ចំណែកនៅខេត្តចូវដុកវិញ ខ្មែរមានចំនួន(១/៣) មួយភាគបីគឺ៤០,០០០នាក់ ទល់នឹងយួន១៦៤,០០០នាក់ ។ បើសិនគេស្រង់យកតែលក្ខណៈទូទៅ ក្រៅពីខេត្តត្រាវិញ គេសង្កេតឃើញថា គ្រាន់តែនៅភូមិភាគកាត់ទន្លេបាសាក់ ( le seul Tranbassac ) ប៉ុណ្ណោះ សហគមខ្មែរមានរហូតដល់ទៅដប់ប្រាំមួយភាគរយ (១៦%) នៃចំនួនជនជាតិសរុបទាំងអស់ ។

នៅក្នុងភូមិភាគត្រាវិញនិងសុកត្រាំង អ្នកដែលមានកំណើតនៅក្នុងស្រុកស្រាប់ ( les autochtones ) បានតាំងលំនៅជិតៗគ្នាណែនណាន់តាន់តាប់ ។ ក្នុងឆ្នាំ១៩

៣៧ ខេត្តទី១នៅក្នុងបណ្តាខេត្តទាំងពីរខាងលើនេះ ប្រជាពលរដ្ឋខ្មែរបានរក្សាទុកនូវលក្ខណៈច្រើនលើសលប់ ( la position dominante ) ជាងសាសន៍ដទៃទៀតនៅក្នុងបណ្តាភូមិទាំងហាសិប (៥០) និងមានចំនួនភាគច្រើន ( la majorité ) នៅក្នុងភូមិជាងម្ភៃទៀត ។

ពួកគេរស់នៅជុំវិញវត្តអារាមរបស់ពួកគេដែលមានចំនួន១០៩វត្ត និងមានព្រះសង្ឃចំនួន១,៣០០អង្គ ។ គឺវត្តទាំងអស់នេះហើយ ដែលបានបង្ហាត់បង្រៀនផ្លូវធម៌, ផ្លូវព្រះពុទ្ធសាសនា ។

នៅខេត្តសុកត្រាំង គេរាប់ឃើញវត្តមិនតិចជាង៥៩វត្តឡើយ ហើយគេថែរក្សាបុគ្គលិកលក្ខណៈជាតិសាសន៍ឲ្យស្ថិតនៅជាខ្មែរជានិច្ច ។ ពួកគេបានថែរក្សាទុកយ៉ាងម៉ឺងម៉ាត់នូវអត្តសញ្ញាណជាតិតាមរយៈ « សមាគមអប់រំសីលធម៌-ដំរេះវិជ្ជា និងសរីរាងកាយនៃខ្មែរនៅកូសាំងស៊ីន Association pour la formation morale - intellectuelle et physique des Cambogiens de Cochinchine » ដឹកនាំដោយ លោកឡាំ-ឯម ។ ( ក.អ.ប.ប. ៖ ក្រោយមកសមាគមនេះបានប្រែឈ្មោះជា មិត្តសមាគមខ្មែរនៅកម្ពុជាក្រោម Amical des Khmers du Kampuchea Krom -A.K.K. ហើយសព្វថ្ងៃមានបណ្តាញនៅក្នុងប្រទេសកម្ពុជា, សហរដ្ឋអាមេរិក, ប្រទេសបារាំង, កាណាដា, អូស្ត្រាលី, នូវែលហ្សេឡង់... ) ។

នៅភូមិភាគចន្លោះកណ្តាល កាត់ដោយទន្លេបាសាក់ ភូមិនានារបស់ជនជាតិខ្មែរស្ថិតនៅជុំគ្នា ដូចជាភូមិអូរនិងភូមិត្នោតជាដើម ។

នៅខេត្តរាច់-យ៉ា ( ខេត្តក្រមួនស ) ភូមិខ្មែរទាំងឡាយស្ថិតនៅហាក់បីដូចជាកោះពង្រាយពាសពេញ នៅប៉ែកខាងជើងនិងប៉ែកខាងត្បូងនៃទីប្រជុំខេត្ត ។ ក៏ប៉ុន្តែនៅខេតចូវ-ដុកវិញ នៅតាមបណ្តោយជួរភ្នំទ្រីតុង ( Triton ) ភូមិខ្មែរបន្តបន្ទាប់គ្នាហូរហែកកកុញ ដោយបានរក្សាទុកយ៉ាងមធ្យ័ត នូវទំនៀមទម្លាប់តាំងពីបុរាណកាលរៀងមក ។ ភូមិខ្មែរខ្លះទៀត ស្ថិតនៅឯណោះខ្លះឯណោះខ្លះ ( des éléments sporadiques ) គេរមែងប្រទះឃើញនៅក្នុងខេត្តឡុង-ស្វៀង, យិន-ឡុង, តឹង-អាង និងនៅទីក្រុងចើ-ឡើងផងដែរ ។ ចំណែកនៅឯនាយបឹងកកឯណោះ ( au delà Plaine des Joncs ) គេរមែងប្រទះឃើញភូមិខ្មែរលេចចេញជារូបរាងឡើង នៅពេលដែលគេកាន់តែទៅជិតដល់ព្រំប្រទល់ដែនប្រទេសកម្ពុជា ពោលគឺនៅក្នុងភូមិភាគខេត្តតៃនិញ ។

ប្រជាពលរដ្ឋខ្មែរបានគេចចេញពីភូមិភាគកណ្តាល ដូចជាខេត្តមី-ថ, ខេត្តបេនត្រែ ឬខេត្តហ្គោ-កុង ព្រមទាំងពីអាណាខេត្តទាំងឡាយនាទិសបូព៌ា ដូចជាខេត្តបារៀ ក៏ប៉ុន្តែគេក៏នៅរាប់ឃើញថា នៅមានជនជាតិខ្មែររាប់ពាន់នាក់ផងដែរ នៅក្នុង

ខេត្តបៀង-វ៉ា និងខេត្តធូ-យ៉ូវម៉ោក ( ខ្មែរយើងហៅថា ខេត្តទួលតាមោក ) ដែលជាសំណល់ចុងក្រោយបង្អស់ ( dernier vestige ) នាភូមិភាគខាងកើត បន្ទាប់ពីត្រូវពួកយួនឈ្លានពានប្រវ័ញ្ចយកបានមកហើយ ។

ទោះបីប្រជាពលរដ្ឋទាំងនោះបានគេចភៀសខ្លួន ចេញទៅកន្លែងដទៃបាត់ទៅហើយក៏ដោយ ក៏ដែនដីមួយភាគធំរបស់ពួកគេ នៅតែបន្សល់ទុកនូវអនុស្សាវរីយ៍ដ៏សែនជូរចត់ ដែលនៅតែត្រូវបានរក្សាទុកនៅក្នុងប្លង់ផែនទីប្រវត្តិសាស្ត្រ កំណត់ថាជាស្រុកទេសរបស់គេដដែល ។ ឈ្មោះស្រុក-ភូមិ-តំបន់ខ្លះៗ វាគ្រាន់តែកែប្រែពីឈ្មោះដើមជាខ្មែរតែប៉ុណ្ណោះ ។ ដូចនេះហើយ បានជាគេងាយយល់ងាយស្គាល់ជាទីបំផុត ដូចជា ៖ ខេត្តសាដែក ( Sa Dec ) ក្លាយមកពីពាក្យខ្មែរ : ផ្សារដែក ( le marché de fer ) ជាដើម...។ ពាក្យ Sôc Trang មកពីពាក្យ : ស្រុកឃ្លាំង ( le pays des greniers ) ។ ខេត្តត្រា-វិញ Tra Vinh ឬខេត្តព្រះត្រពាំង ។ ខេត្ត Bac Liêu ឬ ខេត្តពោធិលើ ( Pô-Loeuh : le haut banian ) ( ដល់ពេលក្រោយមកខ្មែរហៅក្លាយទៅជា : ពលលាវ ព្រោះមានមេទ័ពជាតិលាវម្នាក់ បាននាំពលសេហ៍ទៅច្បាំងកាប់សម្លាប់ដេញយួននៅទីនោះ ត្រង់តំបន់បាភ្នំ (១៧២០) នៅក្រោយរាជស្តេចជ័យជេដ្ឋាទី២ ) ។ ខេត្ត Camau ឬទឹកខ្មៅ ( Tuk Khmau ) ទឹកខ្មៅ les eaux noires ។ ខេត្តមី-ថរ My Tho ឬ Mê Sar ( la dame blanche ) មកពីពាក្យខ្មែរថា ខេត្ត មេ-ស ។ល។ និង ។ល។...

ឈ្មោះដទៃទៀតជាការបកប្រែស្មោះតែម្តង ជាពាក្យយួនពីឈ្មោះដើមជាខ្មែរដូច្នេះហើយបានជាគេឃើញថា ខេត្តបេនត្រែ Bên Trê - la berge des bambous ( យួន : Bên ប្រែថាចំណត ដូចជាចំណតឬបេនឡាន, កំពង់ឆ្លង... និងត្រែ Trê ប្រែថាដើមឫស្សី ) ក្លាយមកពីពាក្យខ្មែរថា : ខេត្តកំពង់ឫស្សី ។ តំបន់ Bên Nghê ( Nghê ប្រែថាក្របី ) la berge des bufflons ដែលជាឈ្មោះដើមនៃភូមិភាគតូចមួយស្ថិតនៅជាយទីក្រុងព្រៃនគរ... តាមរយៈឈ្មោះនេះគេអាចយល់បានយ៉ាងងាយថា មកពីពាក្យខ្មែរ : កំពង់ក្របី ។ ម្យ៉ាងវិញទៀត ឈ្មោះពីបុរំបុរាណខ្លះៗទៀតគេរកតែមើលមិនយល់ ក៏ប៉ុន្តែឈ្មោះទាំងនោះនៅតែបានប្រជាពលរដ្ឋយកមកប្រើជានិច្ច ឥតដែលបោះបង់ចោលសោះឡើយ ដូចជារោងដំរី « l'enclos des éléphants » សំរាប់សំគាល់ខេត្តតៃ-និញ ។ ឡុង-ហោ « le devin noyé » ជាឈ្មោះខេត្តវិញ-ឡុងសព្វថ្ងៃ ។ ខេត្តមាត់ជ្រូក « le groin du porc » ទៅជាខេត្តចូវ-ដុក។ ខេត្តក្រមួនស « la cire blanche » ទៅជាខេត្តរ៉ាច់-យ៉ា ។ ខេត្តពាម « Peam » l'embouchure ទៅជាខេត្តហាទៀង Hatiên និងជាពិសេសក្រុងព្រៃនគរ ( Prei Nokor : du sanskrit Nagara - la ville de la forêt ) សំរាប់ហៅឈ្មោះជា Saïgon-



រូបថតព្រះវិហារវត្តពោធិសាលរាជ ( វត្តកំពង់ ) ជាវត្តដែលខ្មែរទូទៅនៅក្នុង
ខេត្តព្រះត្រពាំង តែងនាំគ្នាមកធ្វើពិធីបង្សុកូលជូនឧកញ៉ាសឺន-គុយ ។ វត្តនេះ
កសាងដំណាលគ្នានឹងវត្តសំរោងឯក ( សតវត្សទី៧ ) ។ មានវត្តបីទៀតដែល
មានចំណាស់ដូចគ្នាគឺ ៖ វត្តខ្ទឹង, វត្តកោះ និងវត្តគោក ។ Photo: Thach Xé

Cholon ពោលគឺទីក្រុងនេះហើយដែលជាអតិតរដ្ឋធានី (បូរី) របស់ខ្មែរ ដែលផ្ទៃមួយភាគធំបានលាតសន្ធឹងទៅលើវាលផ្នូរខ្មោច ឬវាលរហោឋាន ( une partie de la Plaine de Tombeaux ) មួយផ្នែកដែរ ។ ដូចគេបានឃើញរួចមកហើយស្រាប់ ពាក្យឬឈ្មោះស្រុក-ភូមិ-តំបន់ទាំងឡាយនោះ វាមានទំនាក់ទំនងទៅនឹងធនធានធម្មជាតិ ជួនទៅនឹងលក្ខណៈធម្មជាតិ ហើយជាទូទៅច្រើនមានន័យច្បាស់លាស់ទៀតផង តែត្រូវគេបំភ្លៃពីឈ្មោះដើម ឬលប់ចោលបំបាត់តាងស្មោះតែម្តង ជាពិសេសដើម្បីសំគាល់ឈ្មោះភូមិនានា ដោយគេរើសយកតាមពាក្យយួន-ចិននិយមហៅ ដោយចែងប្រាប់ឬថ្លែងបញ្ជាក់ពីបំណងចង់បានភាពសំបូរសប្បាយ, សុភមង្គល ឬភាពចំរើនលូតលាស់ ។ កិច្ចការផ្នែករដ្ឋបាលរបស់យើងរមែងបានយកចិត្តទុកដាក់ចាប់អារម្មណ៍ជានិច្ច ចំពោះឈ្មោះទាំងឡាយដែលគេយកមកដាក់ជំនួសឈ្មោះដើមទាំងនោះ ។ ជាពិសេសនៅពេលដែលផ្នែករដ្ឋបាយរបស់យើងស្វែងរកដើមហេតុដែលចេញមក ក្នុងកិច្ចរៀបចំបង្កបង្កើតប្រមូលផ្តុំទៅជាភូមិ-ឃុំ- ស្រុកទាំងនោះ ថាអាចសំអាងទៅលើលក្ខណៈសេដ្ឋកិច្ច ឬទៅលើការងាយស្រួល ។ មានជួនកាលឈ្មោះថ្មីជាភាសាយួនដដែលហ្នឹង វាឥតមានទាំងន័យទៅទៀត ហើយដែលការបោះពុម្ពផ្សាយជាបន្តបន្ទាប់នូវផែនទីដែលផ្សាយចេញ ពីក្រសួងផែនទីភូមិសាស្ត្រ ( Service Géographique ) ក៏ពុំបានទាំងស្រាវជ្រាវតាមដានឲ្យបានច្បាស់លាស់ពីការកែប្រែផ្លាស់ប្តូរតាមអំពើចិត្តដោយគ្មាននរណាជំទាស់បែបនេះ ( ces modifications arbitraires ) នៅលើវិទ្យាសាស្ត្រខាងលើកប្លង់ផែនទី ។ ខ្ញុំបានស្គាល់ភូមិមួយនៅក្នុងខេត្តរ៉ាច់-យ៉ា ដែលមានឈ្មោះដើមថា Ban Thach មានន័យថា «តុថ្ម» ( table de pierre ) បានក្លាយទៅជា Ban Tân Dinh ដោយរំលាយឈ្មោះភូមិ Ban Thach និងភូមិ Tham Dinh ចូលគ្នា ដែលអំណើះតទៅឈ្មោះនេះឥតមានន័យអ្វីទាល់តែសោះ ។ តែឈ្មោះភូមិថ្មីនោះបានទាញចិត្តខ្ញុំឲ្យចាប់អារម្មណ៍យ៉ាងខ្លាំងពីឈ្មោះចាស់ ( ឈ្មោះដើមដំបូង ) ព្រោះវាចម្លែកមិនដូចសព្វដង ។ ខ្ញុំក៏បានទៅធ្វើទស្សនកិច្ចពិនិត្យដល់ទីកន្លែង ហើយដែលការទៅធ្វើការអង្កេតពិនិត្យរបស់ខ្ញុំនោះ វាមិនឥតប្រយោជន៍ឯណា ព្រោះជាហេតុញ៉ាំងឲ្យខ្ញុំបានស្គាល់ជាចុងបញ្ចប់ថា « តុថ្ម » ( la table de pierre ) មិនមែនជើងម៉ាវែងធ្វើពីដីក្រហម ( non pas un banc de latérite ) ដូចដែលគេបានបញ្ជាក់ប្រាប់នោះឯណា ? តែវាជាឃ្លាំងដែលផ្ទុកពេញពោរទៅដោយសំបកលាស-គ្រុំ-ខ្យង ហើយដែលមានបណ្តោយរាប់រយម៉ែត្រឯណោះ ទុកជាសំណាមបញ្ជាក់ឲ្យដឹងថា ត្រង់កន្លែងនេះហើយជាច្រាំងឆ្នេរសមុទ្រកាលពីមុនយូរអង្វែងមកហើយ ៗដែលមានរាងជាកូនភ្នំពីរកើតឡើងពីសំបកខ្យង-លាស-គ្រុំ រាងដូចជារបស់រៀបចំសំរាប់ប្រើប្រាស់ក្នុង



រូបថតសាលាឆទានវត្តទេព្វរាម ( ព្រៃជាប់ ) ខេត្តឃ្លាំង Photo: Thach Xé

ផ្ទះ លាយឡំដោយអំបែងដប, កែវ, ផើង, ចាន ហើយមានទំនាក់ទំនងទៅនឹងការនៅជិតបារាយណ៍ ( ទន្លេបាទី) ដ៏ធំធេងនេះ ( dans cet immense emporium) ដែលមានផ្ទៃក្រឡារហូតដល់ទៅជាង៤០០ហិកតានោះ ក៏ហាក់បីដូចជាមានការជាប់ទាក់ទងជាមួយគ្នានឹងហ្វូងប្រជាជន ដែលដើរជ្រកតាមប្រទេសនានា ( la population cosmopolite ) ពីព្រោះគេបានរុករកឃើញនៅលាយឡំគ្នា ច្រូបូកច្របល់នូវរបស់របរប្រើប្រាស់ផ្សេងៗ ដែលបញ្ជាក់ពីឥទ្ធិពលឥណ្ឌូណេស៊ី, ឥណ្ឌូ, មន, ឥណ្ឌា, អៀវ៉ានីញៀង នៃប្រទេសក្រិកជំនាន់ដើម ព្រមទាំងប្រទេសរ៉ូម៉ាំងថែមទៀតផង ។

បើប្រសិនជាគេសង្កេតពិនិត្យពីលើអាកាសមក ទស្សនិយភាពទាំងនេះចង្អុលបង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋទាំងនោះយកបានជោគជ័យជំនះលើទឹក ដោយមានប្រឡាយបញ្ចូលទឹកឬបង្ហូរទឹកតាមបំពង់ ( drainage ) ព្រមទាំងបានជីកប្រឡាយព្រែកដ៏ធំសម្បើម ដែលគេនៅតែរុករកឃើញស្លាកស្នាមនៅឡើយ រហូត

តដល់ទៅតំបន់ភូមិភាគដែលលិចទឹកពាក់កណ្តាលនាវាលកក់ ( les terres semi-noyées de la Plaine des Joncs ) ។ យ៉ាងហោចណាស់ក្នុងរយ:ពេលជាង៣០ឆ្នាំចុងក្រោយនេះដែរ ដែលនៅតំបន់ភូមិភាគនានាតាត់តាមទន្លេបាសាក់ សឹងតែពោរពេញទៅដោយព្រៃស្មសានក្រាស់ឃ្មឹកធំល្វឹងល្វើយ ហើយជនទាំងឡាយណា ដែលបានវែកញែកត្រួសត្រាយ បើកផ្លូវអាណានិគមថ្មីមុនគេបង្អស់មកកាន់ភូមិភាគនេះ ប្រាកដជាបានសារសងជាមួយពួកជនដែលពេញចិត្តនឹងខ្លួនឯងទាំងនោះ ដោយជឿជាក់ថា មានតែពួកគេដែលបានកាប់ឆ្ការវាតទីក្នុងព្រៃដ៏ស្ដុកនាទីនេះមុនគេបង្អស់ ។ តាមពិតមានប្រជាជនដ៏ច្រើនកុះករបានរស់នៅទីនេះពីដើមរៀងមកលើទឹកដី ( ពាក់កណ្តាលទឹក-ពាក់កណ្តាលដីគោក ) ហើយឃោលទៅលើចម្លាក់កត់ត្រាលើថ្មដែលគេប្រទះឃើញនាសតវត្សទី៥ ត្រង់តំបន់ភូមិភាគកណ្តាលនៃវាលបឹងកក់នោះ ជាការបង្ហាញបញ្ជាក់ឲ្យឃើញពិតប្រាកដថា ត្រង់តំបន់នេះដែលសព្វថ្ងៃជាវាលល្ហល្ហេវហួតហែងឥតមានមនុស្សនៅស្នាត់ជ្រងំនោះ តែកាលពីសម័យដើម ទីត្រង់នេះត្រូវបានពពួកមនុស្សយកជ័យជំនះលើតំបន់ភក់ល្បប់ជាដំបូងបង្អស់ ។ ខ្ញុំគ្មានការប៉ុនប៉ងអ្វីចង់ចង្អុលបញ្ជាក់ថា នៅទីនេះ ភស្តុតាងជាបន្តបន្ទាប់ប្រាប់ថា មានវត្តមានជនជាតិខ្មែរនៅលើទឹកដីកូសាំងស៊ីន ពីសតវត្សមួយទៅសតវត្សមួយទៀតនោះឡើយ ។ សក្ខីភាពភស្តុតាងដែលស្រាវជ្រាវរកបានមកទាំងអម្បាលមាណតាំងពីជាង១០ឆ្នាំកន្លងមកហើយនោះ រហូតមកទល់នឹងពេលនេះគេឃើញមានរាប់រយទៅហើយ ។ នៅក្នុងប្រទេសនេះ គេបានរុករកឃើញនៅតាមទីសក្ការ:បូជា កន្លែងពិសិដ្ឋនូវពំនូកថ្មក្បឿង ដែលជាគ្រឹះសំណល់ដែលនៅសេសសល់នៅតាមវត្តអារាមនានា រវាងសតវត្សទី៦ ឬប្រហែលជាមុននេះទៅទៀតផងក៏មិនដឹង នៅតាមខេត្តខ័ណ្ឌទាំងឡាយ ដូចជានៅខេត្តរ៉ាច់យ៉ា, ត្រាវិញ, បេន-ត្រែ, Cap St. Jacques ហើយនិងនៅវាលកក់ ។ រូបព្រះព្រហ្មណ៍សំរាប់គោរពបូជា ( les Idoles brahmaniques ) ជាពិសេសព្រះក្នុងព្រហ្មញ្ញសាសនាមានចំនួនច្រើនជាអនេក ហើយនៅរាយប៉ាយគ្រប់ទិសទី ។ ក៏ប៉ុន្តែការគោរពបូជាចំពោះព្រះសិវ:វិញ វាមានការច្របូកច្របល់គ្នា ទៅជាមួយនឹងព្រះអាទិទេព ដែលកើតមានឡើងនៅស្ទើរគ្រប់ទីកន្លែង និងជានិមិត្តរូបនៃបូរាណភាពផ្នែកនយោបាយ ។ ទីប្រជុំជនជាច្រើនបានត្រូវកសាងឡើងនៅលើដីសណ្តទន្លេមេគង្គ ( le Delta ) ដូចជានៅព្រៃនគរ ឬ Saigon-Cholon ជាដើម ។ ទីប្រជុំជនកំពង់ផែ Oc-Eo នៅត្រង់ភូមិភាគកាត់ទន្លេបាសាក់ ( le Transbassac )- ប្រាសាទ១០០ល្វែងនៅត្រង់វាលប-ក្សាបក្សី ( la plaine des Oiseaux ) នាប៉ែកខាងជើងខេត្តទឹកខ្មៅ ។ នាសតវត្សទី១១ អធិបតេយ្យភាពខ្មែរបានលាតសន្ធឹងយ៉ាងពិតប្រាកដណាស់ ទៅលើតំបន់សុក

កទ្រាំង នៅជុំវិញកំពង់ផែបាសាក់ ។ ពីរសតវត្សក្រោយមក សក្ខីភាពបានបញ្ជាក់យ៉ាងច្បាស់ ពីសំណង់មន្ទីរព្យាបាលរោគទាំងឡាយដែលសង់ឡើង ជាពិសេសក្រោមព្រះរាជកិច្ចចាត់ចែងរបស់ព្រះមហាក្សត្រដ៏ឧត្តុងឧត្តមជាងគេបង្អស់ គឺព្រះបាទជ័យវរ្ម័នទី៧ ដូចដែលគេតែងប្រទះឃើញនៅក្នុងខេត្តកឹង-ថើ ( ខេត្តព្រៃកប្បិ ) ។ នៅចុងក្រោយគេបង្អស់ នៅមានរឿងព្រេងនានារបស់ខ្មែរឬរបស់យួន ព្រមទាំងសំណេរកត់ត្រារបស់អ្នកដំណើរ ឬក៏បេសកជន ( les missionnaires ) ទៀត ក៏រឹតតែបញ្ជាក់យ៉ាងច្បាស់លាស់ថា ទឹកដីត្រង់នេះត្រូវបានខ្មែរត្រួតត្រាកាន់កាប់ជារៀងរហូតមក យ៉ាងជាប់លាប់មិនឲ្យបាត់បង់ឡើយ ( avec persistance ) ហើយព្រឹត្តិការណ៍អស់ទាំងនេះ ត្រូវបានជនជាតិចាមនៃនគរចំប៉ាបានបញ្ជាក់ថែមទៀត នៅពេលដែលចាមកំពុងតវ៉ាប្រឆាំងនឹងការឈ្លានពានរបស់យួនទាំងក្តីអស់សង្ឃឹម ។

កម្ពុជាដែលពីដើមជាអធិរាជាណាចក្រមួយដ៏ទូលំទូលាយ (un immense empire ) ក៏ត្រូវប្រឈមមុខនឹងការបែកបាក់ជាបំណែកៗនាសតវត្សក្រោយៗរៀង មកនៅចំពោះមុខគូប្រជែងទាំងពីរ ដែលរមែងតែងតែប្លន់យកដោយបំពាននូវទឹកដីកម្ពុជា គឺពីនគរអណ្ណាមនៅប៉ែកខាងកើត និងពីប្រទេសសៀមនៅប៉ែកខាងលិច ។ ព្រំសីមាផ្នែកនយោបាយរបស់កម្ពុជានាពេលនោះ មានភាពស្របគ្នាមកទល់បច្ចុប្បន្នកាលនេះ ពោលគឺលាតសន្ធឹងគ្របឥទ្ធិពលទៅលើប្រទល់ដែនដែលជាតិសាសន៍ផងខ្លួនរស់នៅ ( à ses groupements ethniques ) ។

នៅប្រទេសសៀម បើប្រសិនគេមិនគិតទៅលើតំបន់ Alsace Loraine (ព្រំដែនបារាំង-អាល្លឺម៉ង់ ) គឺតំបន់បាត់ដំបង, ស៊ីសុផុននោះទេ ក៏គេនៅតែឃើញមានជនជាតិខ្មែរយ៉ាងច្រើន ដែលជាស្នូលនៃជនជាតិមានដើមកំណើតដំបូងគេបង្អស់នៅត្រង់តំបន់ទំនាបនៃខេត្តកូរ៉ាត ក្នុងតំបន់បូរីរ៉ាម នៅសុរិន នៅគោកខ័ណ្ឌ នៅប្រាជិមបូរី ( បសី្លមបុរី ) រហូតទៅទល់នឹងតំបន់នាជិតបាងកក ។ ជនជាតិខ្មែរមានចំនួនប្រមាណ៤៥០,០០០នាក់ បានបង្ហាញបញ្ជាក់ចំពោះពួកអ្នកទទួលខុសត្រូវនៃបសី្លមប្រទេសឲ្យឃើញថា ខ្មែរនៅសៀមក៏មានប្រហាក់ប្រហែលនឹងខ្មែរនៅដែនកូសាំងស៊ីនផងដែរ ហើយខ្មែរទាំងឡាយនោះ ជាសំណល់ក្រោយពីការហិនហោចដោយសារចំបាំងរាំងជល់ នៃអតីតមហាអំណាចផ្នែកនយោបាយរបស់ខ្មែរដែលនៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ បានគ្រប់ដណ្តប់ទៅលើប្រទេសសៀមសព្វថ្ងៃទាំងមូល ដោយរួមទាំងដែនដីនៃជ្រោយម៉ាឡាកា ( ម៉ាឡាយូ ) មួយផ្នែកផង រួចឈោងទៅដល់ផ្នែកខាងជើងនៃប្រទេសភូមា ព្រមទាំងផ្នែកខាងលើនៃប្រទេសលាវ - លាតសន្ធឹងលើដែនដីកូសាំងស៊ីនទាំងមូល អស់រយ:១/៤នៃសតវត្ស



រូបថតវត្តជយសត្ថារតនារាម ( ចេកជ្រៃ ) កសាងនៅសតវត្សទី១៨ នៅស្រុកផ្ដៅ
ដាច់ ខេត្តព្រះត្រពាំង ) ប្រទេសកម្ពុជាក្រោម ។ នេះជាវត្តដែលព្រះតេជព្រះគុ-
ណាសឹង-វង់ ធ្លាប់គង់នៅ - ព្រះអង្គជាមេដឹកនាំខ្មែរក្រោមដ៏ក្លាហានអង់អាចមួយ
អង្គ ត្រូវយួនចាប់យកទៅធ្វើគតនាឆ្នាំ១៩៥៨ នៅខេត្តទឹកខ្មៅ ។ Photo: T. Xé

(២៥ឆ្នាំ)-រក្សាទុកឲ្យនៅភាពដដែលរហូតដល់កណ្តាលបេះដូងនៃនគរអាណ្ណាម នាពេលបច្ចុប្បន្ន - ត្រង់តំបន់ប៉ិញ-ឌីញ ។

អំពើវិត្ថារកម្មពង្រីកទឹកដីរបស់យួនមកលើដែនដីកូសាំងស៊ីន បានចាប់ផ្តើមបង្ហាញឡើង ក្នុងលក្ខណៈជាផ្លូវការក្នុងឆ្នាំ១៦៥៨ ។ នាដើមសតវត្សនោះ ប្រជាជាតិយួននេះដែលទទួលជ្រួតជ្រាបតាមវប្បធម៌ចិន បាននាំគ្នារូតរះដឹកកូនជញ្ជូនចៅមកកាន់តំបន់ជួរភ្នំអណ្ណាមតាមបណ្តោយឆ្នេរសមុទ្រ បណ្តាលឲ្យបាត់បង់ខូចខាតទៅលើទឹកដីនៃអតិតនគរចំប៉ា ដែលជាព្រះរាជាណាចក្រមួយទទួលនូវវប្បធម៌អារិយធម៌ពីប្រទេសឥណ្ឌា ហើយដែលចលនាតស៊ូរំដោះនៃប្រទេសចាម កំពុងតែហេវហាត់នឿយណាយអស់មានកម្លាំងនឹងទប់ទល់តទៅទៀតកើត ។ ក្នុងឆ្នាំ១៦០២ ពពួកយួនបានមកដល់ខេត្តគី-ញ៉ើង ( Qui Nhon ) រួចបានឆ្លងកាត់តាមតំបន់វ៉ារ៉ែលឡា ( le Varella ) ។ ក្នុងឆ្នាំ១៦៥៣ យួនបានតែងតាំងដោយខ្លួនឯងនូវតំបន់រដ្ឋបាលផ្ទាល់របស់គេមួយ ដោយរួមបញ្ចូលយកខេត្តញ៉ាត្រាង និងខេត្តផាន់-រ៉ាំង មុននឹងបញ្ចូលទៅក្នុងខេត្តផាន់-ធៀត រួចឈោងទៅយកមករួមបញ្ចូលក្នុងអាជ្ញាធររបស់ខ្លួននៅតំបន់ដូនណៃ និងតំបន់បាន់ស្មី ពោលគឺភូមិភាគបៀនវ៉ា និងបាៀរ ។

ខ្ញុំឥតមានទទួលភារៈនឹងថ្លាថ្លែងឲ្យបានក្បោះក្បាយនូវប្រវត្តិនៃការចំរើនលូតលាស់ នាជ្រោយទន្លេមេគង្គនោះឡើយ ។ តែខ្ញុំសូមអនុញ្ញាតរាប់បញ្ចូលនូវដំណាក់ការសំខាន់ៗតែប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៦៩៨ នៅលើភូមិភាគដូនណៃទាំងមូល ត្រូវបានជនជាតិយួនរំដោះយកបានហើយ ត្រូវចែកចេញជា៣ខណ្ឌឬមណ្ឌលស្របនឹងពេលសព្វថ្ងៃនេះ គឺមណ្ឌលបៀងវ៉ា, យ៉ាឌីញ និងព្រៃនគរ ។

ក្នុងឆ្នាំ១៧១៥ ប្រទេសយួនបានទទួលយល់ព្រមដោយឥតអៀនខ្មាស់ យល់ព្រមឲ្យអ្នកផ្សងព្រេងជាតិចិនម្នាក់ បែងចែកទឹកដីនេះជាតំបន់ស្វយ័តនាតំបន់ហាតៀង ។ ក្នុងរយៈពេលពេញមួយសតវត្សទី១៨នោះ យួនបានយកចិត្តទុកដាក់រួមបញ្ចូលជារបស់ផងខ្លួន នូវដែនដីភាគខាងកើតទាំងអស់ រួចភ្ជាប់ទៅនឹងទឹកដីភូមិភាគខាងលិច ដែលខ្លួនតើបប្រវ័ញ្ចយកបានថ្មោងថ្មី ។ ក្នុងឆ្នាំ១៧៣២ យួនបានបែងចែកជាខេត្តខ័ណ្ឌ-រដ្ឋបាល សំរាប់ជាប្រយោជន៍របស់ផងខ្លួន នៅក្នុងខេត្តលង់-ហោ ពោលគឺវិញ-ឡុង ភ្ជាប់ទៅនឹងតំបន់ឆ្នេរសមុទ្រ រហូតដល់ត្រាវិញ និងបាសាក់ ។

ឆ្នាំ១៧៥៣ ពួកយួនលេបយកភូមិភាគមី-ថរ ដោយក្តោបយកខេត្តនានានៅប៉ែកខាងជើងនៃទន្លេមេគង្គខាងក្នុង ( au Nord du Fleuve Antérieur ) ។ ឆ្នាំ១៧៥៧ យួនជំរុលរហូតទៅដល់ចំណុចចុងបំផុត ដល់ខេត្តមាត់ជ្រូក ( ចូវដុក ) ដោយមាន

បញ្ចេញឥទ្ធិពលផ្សាភ្ជាប់បែបនេះទៅនឹងទឹកដីទាំងអស់ដែលខ្លួនប្លន់យកបាន ចាប់ពីជើងទៅត្បូង រួចបែរត្រឡប់ទៅទិសខាងលិចទៀត ។ ការកើតឡើងបះបោរនៃពួកតៃសើងនាដំណាច់ចុងសតវត្សទី១៨ បានបណ្ដាលឲ្យមានការបង្ករឈាមពាសពេញនគរ អស់រយៈពេលយ៉ាងយូរ គឺ២៥ឆ្នាំឯណោះ ជាហេតុបង្អាក់បន្ថយដំណើរឈ្លានពានទៅលើទឹកដីខ្មែរតទៅទៀត ហើយដែលនៅត្រង់កន្លែងខ្លះទៀត ពួកយួនគេតែងពង្រីកពង្រឹងឲ្យរឹតតែរឹងប៉ឹងមាំឡើងតទៅទៀត ។ ក៏ប៉ុន្ដែជាការកត់សំគាល់មួយដោយឡែកថា ៖ នាឆ្នាំ១៨៣២ គឺប្រមាណជិត៣០ឆ្នាំមុនការមកដល់នៃដំណើរបេសកកម្មស្រាវជ្រាវរបស់បារាំង- អេស្ប៉ាញ៉ុលក្នុងឆ្នាំ១៨៥៩-១៨៦០ ដែលព្រះចៅអធិរាជមិញ-ម៉ាង បានចាប់ផ្ដើមរៀបចំចាត់ចែងបង្កបង្កើតជាតំបន់រដ្ឋបាលនៅលើដែនដីកូសាំងស៊ីន រួចគឺចាប់តាំងពីពេលនោះមក ហើយដែលមានការផ្លាស់ប្ដូរកែប្រែឈ្មោះខេត្តខ័ណ្ឌទាំងឡាយដូចមានជាប់មកដល់សព្វថ្ងៃនេះ ។

កាលបរិច្ឆេទទាំងប៉ុន្មានដែលខ្ញុំលាតត្រដាងរៀបរាប់ខាងលើនេះ គ្រាន់តែបញ្ជាក់បីការអនុញ្ញាតឲ្យធ្វើតាមបណ្ដោយតែម្ដងជាផ្លូវការ នៃការសរសៀវខិតលយចូលបន្ដិចម្ដងៗ ឬការរំលោភបំពានដោយអំណាចនៃពួកយួនទៅលើដែនដីកូសាំងស៊ីនតែប៉ុណ្ណោះ ។ ដំបូងឡើយ ពួកយួនឈ្លានពានទាំងនោះ សុទ្ធតែជាអ្នកដើរផ្សងព្រេង ជាជនពាលអនាថា ជាជនត្រូវគេនិរទេសព្រោះរឿងនយោបាយជាជនរត់ចោលកងទ័ពឬក៏ជាជនដែលគ្មាន ឈ្មោះចុះក្នុងបញ្ជី ( les nom-inscrits ) ពោលគឺជនដែលគ្មានកេរ្ដិ៍អាករទ្រព្យសម្បត្តិអ្វីទាំងអស់នៅក្នុងភូមិកំណើតរបស់ខ្លួន ។ ដូច្នេះជាចាំបាច់ អាជ្ញាធរតាមភូមិ-ឃុំ តោងតែបណ្ដេញចេញឲ្យទៅរកមធ្យោបាយរស់នៅកន្លែងដទៃទៀតដោយខ្លួនឯង ។ រួចបន្ដមកទៀត មានបណ្ដាជនដែលត្រូវគេដឹកនាំចេញមក ជាពិសេសពីខេត្តក្វាងប៉ិញ និងពីខេត្តប៉ិញ-ឌីញ ។ នៅទីបញ្ចប់ គឺពពួកនិគមជនយោធា ( les colons militaires ) តែម្ដង យ៉ាងច្រើនសន្ធឹកសន្ធាប់មីរដេរដាស់ មកនាំគ្នាបង្កើតភូមិថ្មីៗ ជាពិសេសនៅត្រង់តំបន់ផ្នែកកណ្ដាល និងផ្នែកខាងលិចដែនកូសាំងស៊ីន ។

ការចាប់ផ្ដើមតាំងទីនៅជាប់លាប់រហូតនៃពួកនិគមជនយួន ដែលទើបមកដល់ថ្មីៗទាំងអស់នោះ បានជួបប្រទះនូវលក្ខណៈល្អប្រពៃ សំរាប់ពួកគេរស់នៅចំពេលដែលសង្គ្រាមរបស់ពួកតៃ-សើង ធ្វើឲ្យស្ដេចនគរអណ្ណាមហិនហោចទ្រព្យសម្បត្តិអស់រលីង ក៏នាំគ្នាមកសុំជ្រកកោននៅដែនកូសាំងស៊ីនប៉ែកខាងក្រោម ( dans la période de la guerre des Tay Son où le souverain d'Annam dépossédé-trouva refuge en Base-Cochinchine ) ។ ដោយឆ្លៀតនឹងឱកាសកោលាហលច្របូកច្របល់នេះ ប្រជាជនខ្មែរអាចកាន់កាប់ដោយផ្ទាល់ នូវអំណាចរដ្ឋបាល




រូបថតព្រះសង្ឃខ្មែរក្រោមចំនួន២៦៥អង្គកំពុងធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីទាមទារនាទីជាជនភាគតិច នៅខាងមុខវិមានប្រធានាធិបតីយួន ( ង្វៀង-វាន់ធីវ ) កាលពីថ្ងៃទី១៣ វិច្ឆិកា ១៩៦៩ ។ **Photo: Thach Xé**

ជាផ្លូវការមួយផ្នែកធំ ហើយគេទាំងបានឃើញថា មានខ្មែរម្នាក់បានជួយគាំទ្រស្ដេចយួនទៀតផង ដោយដឹកនាំអ្នកដែលស្ម័គ្រចិត្តរួមជាមួយខ្លួន ទៅជួយច្បាំងស្ដេចយួនដណ្ដើមយករាជបល្លង្កមកវិញ ។ នយោបាយយួនូបនិយកម្មយ៉ាងខ្លាំងក្លាមែនទែន មិនមែនចាប់ផ្ដើមត្រឹមក្នុងរាជ្យស្ដេចយួនម៉ិង-ម៉ាំងនោះទេ គឺក្រោយឆ្នាំ១៨២០ឯណោះ ។ នៅគ្រប់ទីកន្លែង គេយកមន្ត្រីយួន ( les mandarins ) មកជំនួសមន្ត្រីរដ្ឋបាលខ្មែរ រួចហើយគេធ្វើការគាបសង្កត់ទៅលើបណ្ដារាស្ត្រ ដើម្បីបង្ខិតបង្ខំឲ្យប្រជារាស្ត្រខ្មែរ ទទួលយករបៀបស្លៀកពាក់តាមបែបបទយួន, និយាយភាសាយួន, ទទួលទំនៀមទំលាប់របៀបរបបប្រើប្រាស់ការរស់នៅឲ្យដូចជនជាតិយួន ...។ ពេលនោះខ្មែរទ្រាំលែងបាន ក៏កើតមានការបះឡើង ដោយបង្ហូរឈាមផ្ទុះឡើងនៅខេត្តត្រាវិញក្នុងឆ្នាំ១៨២២ ដែលគេពិបាកនឹងរកឲ្យឃើញនូវប្រភពច្បាស់លាស់ ។ ហេតុនោះហើយ ដែលបានចង្អុលបង្ហាញបញ្ជាក់នៅលើផែនទីចាស់ ។ បន្ទាយតូចៗទាំងនោះឯង មានភារៈសំរាប់ពិនិត្យសង្កេតមើលសកម្មភាពរបស់ប្រជាជនខ្មែរ ។ ក្នុងឆ្នាំ១៨៤១ ការបះបោរមួយទៀតបានផ្ទុះឡើង ដឹកនាំដោយសាសោម (អង្គសា-សោម ?) នៅចំពេលដែលយួនកំពុងតែមានវិបត្តិជាមួយសៀម និងកំពុងលិចលង់ក្នុងអន្លង់លោហិតក្រហមឆ្អិនឆ្អៅសព្វទិសទី ចំបាំងរាំងជល់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ជាសញ្ញាមែនយោបាយសង្កត់សង្កិនយ៉ាងខ្លាំងក្លា និងការដណ្ដើមយកទឹកដីត្រង់នេះដោយបង្ខំ ដោយប្រើកម្លាំង ។ ចាប់តាំងពីពេលនោះតរៀងមក ប្រជាពលរដ្ឋខ្មែរនៅដែនកូសាំងស៊ីន បានលះបង់ចោលកេរ្តិ៍អាករ, ភូមិម្ភូរ, ទឹកដីស្រែចំការ រួចភៀសខ្លួនយ៉ាងច្រើន ( en masse ) ទៅរស់នៅឯប្រទេសកម្ពុជា ។ ក្នុងឆ្នាំ១៨៥៦ មានការបះបោរសារជាថ្មីម្ដងទៀត រួចជាបន្តបន្ទាប់ មានការបះកំរើក២ដងទៀតនៅឆ្នាំ១៨៥៩ និងឆ្នាំ១៨៦១ ។ ទាល់តែយើង (បារាំង) ចូលមកដល់ ទើបខ្មែរនៅដែនកូសាំងស៊ីនអាចចៀសផុតពីការធ្វើទារុណកម្ម ធ្វើបានពីសំណាក់មន្ត្រីអាជ្ញាធរនិងនិគមជនយួនបាន ហើយអាចរកឃើញនូវមនោសញ្ចេតនាខាងសិទ្ធិសេរីភាព ព្រមទាំងការគាំពារមិនឲ្យយួនប្រវ័ញ្ចយកទាំងអស់ ធ្វើឲ្យបាត់បង់កម្មសិទ្ធិដីធ្លី នូវទឹកដីម្តុំទន្លេមេគង្គផ្នែកខាងក្រោម-ខាងត្បូង ( éviction totale du territoire du Bas-Mékong ) ។ ម្យ៉ាងវិញទៀត ការចូលមកដល់របស់យើងជាការអនុញ្ញាតឲ្យខ្មែរនៅដែនកូសាំងស៊ីន អាចថែរក្សាទុកនូវបេតិកភ័ណ្ឌ កេរ្តិ៍មរតកពីបរមបុរាណរបស់គេ ដែលត្រូវរលោះខូចខាតបាត់បង់អស់ជាច្រើនណាស់ទៅហើយ ដោយមធ្យោបាយបំផ្លិចបំផ្លាញចោល គ្មានខ្វល់ខ្វាយគិតគូរពីរឿងប្រយ័ត្នប្រយែង ថែរក្សាទុកឲ្យស្របតាមផ្លូវច្បាប់អ្វីសោះឡើយ ។ ពួកនិគមយួនដែលទើបមកដល់ថ្មីៗ ក៏ចាប់ផ្ដើមរៀបចំទីកន្លែងស្នាក់នៅលើទឹកដីប៉ែកខាងត្បូង ដោយ

ស្របទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ... រួចក៏បង្កបង្កើតតាំងជាភូមិ នៅត្រង់ណាដែលពួកគេយល់ឃើញថា អាចផ្ដល់នូវគុណភាពជាការងាយស្រួលដល់ការរស់នៅ ។ អ្នកកត់ត្រា ( un chroniqueur annamite ) យួនម្នាក់បានសរសេរក្នុងកំណត់ចំណាំរបស់ខ្លួនថា ៖ « ដីឡូទាំងឡាយបានត្រូវគេជ្រើសរើសបែងចែកដោយយោងទៅតាមសេចក្ដីសំរេចរបស់មន្ត្រីនាម៉ឺន ដើម្បីអាចជាកម្មសិទ្ធិរៀងៗខ្លួន ។ គេគ្មានរវល់វាស់វែងអ្វីទៀតទេ ពេលណានរណាម្នាក់ទទួលយល់ព្រមយកជាកម្មសិទ្ធិរួចហើយ ៗក៏គេឥតមានទាំងកត់ត្រាអ្វីជាសំគាល់ផងដែរថា តើជាដីល្អត្រឹមត្រូវតាមក្បួនខ្នាត ឬក៏មិនត្រឹមត្រូវ » ។ អត្ថបទនេះចែងឡើងទុកជាមូលដ្ឋានជាវិធីសំរាប់ការបែងចែកទឹកដីជាទូទៅនៅគ្រប់ទីកន្លែង ដោយគ្រាន់តែសំអាងទៅលើជនណាដែលបានកាន់កាប់នៅនឹងកន្លែង ម្ល៉ោះហើយគោលការណ៍នេះ រស់រានរហូតរាល់ការជ្រៀតជ្រែកទាំងអស់ទៅលើភូមិភាគកាត់តាមទន្លេបាសាក់ ( vers les Transbassac ) ។ ក៏ប៉ុន្តែ ភាគច្រើនអ្នកទើបមកដល់ថ្មីថ្មោង ច្រើនជ្រើសរើសយកទឹកដីត្រង់តំបន់ទំនាប ស្ថិតនៅតាមបណ្ដោយផ្លូវទឹកដែលកើតមានឡើងដោយធម្មជាតិ ។ ហេតុនោះហើយ បើសិនជាគេគ្រាន់តែក្រឡេកមើលទៅលើផែនទីខ្នាត២៥,០០០ គេក៏សង្កេតឃើញថា រហូតមកដល់សព្វថ្ងៃនេះ នៅក្នុងខេត្តត្រាវិញនិងខេត្តសុកត្រាំង នូវការបង្ហាញឡើងពីការចូលចិត្តរបស់គេ ។ ភូមិអ្នកយួនច្រើនស្ថិតនៅតាមមាត់ព្រែក-អូរ-ដៃទន្លេ-សមុទ្រ ពោលគឺនៅតាមផ្លូវទឹក ។ ចំណែកភូមិអ្នកខ្មែរវិញ បានរាយប៉ាយនៅលើដីខ្សាច់តាម « ( Giong ) ផ្ទោរ » ជាហូរហែរ ហើយដែលប្រហែលអាចចាត់ទុកថា បានជាអតិតពំនូកជួរផ្លូវខ្សាច់ដ៏វែងអន្លាយតាមបណ្ដោយឆ្នេរសមុទ្រនោះឯង (d'anciens cordons littoraux) ។ នៅពេលដែលភូមិយួនតែងប្រមូលផ្ដុំផ្ទះជាច្រើននៅតែមួយកន្លែង ដោយមានរុក្ខជាតិដូចជាដើមអំពិលទឹក, ដើមដូង និងដើមស្លា ដ៏ស្រួចស្រាវខ្ពស់លលៃ ។

ឯផ្ទះខ្មែរចូលចិត្តសង់នៅលើទីសួនច្បារ មានរុក្ខជាតិនានា ដាច់ៗពីគ្នាយ៉ាងសង្ហារ ។ ផ្ទះយួនសង់ផ្ទាល់ដី លើកលែងនៅតំបន់ត្រង់ណាដែលមានទឹកជោរជន់រាចមាត់ព្រែក មាត់ទន្លេ ។ ឯផ្ទះខ្មែរ គេចូលចិត្តសង់លើសសរខ្ពស់ផុតពីដី ។ ផ្ទះខ្មែរច្រើនតាំងនៅលើទីទួលស្ងួត មិនសូវមានដើមឈើស៊ុបទ្រុប តែហ៊ុំព័ទ្ធដោយរុក្ខជាតិផ្ដល់នូវផ្លែផ្កាគ្រប់បែបយ៉ាងដូចជា ដូង, ខ្នុរ, ត្របែក, ស្វាយជាដើម...។ ផ្ទះខ្មែរច្រើនសង់នៅត្រង់ដីស្ងួត ដែលនាំមកនូវសុខភាពល្អ ហើយដែលមានទឹកស្អាតបរិសុទ្ធ ។ គ្រាន់តែគេក្រឡេកមើលពីចម្ងាយយ៉ាងធម្មតាសោះ ( ដោយពុំចាំបាច់ពិនិត្យពិច័យ ) គេអាចស្គាល់បានភ្លាមថា ជាទិដ្ឋភាពនៃភូមិអ្នកខ្មែរនៅដែនកូសាំងស៊ីន ប្រកបដោយរុក្ខជាតិខៀវស្រងាត់បន្តហូរហែរវែងអន្លាយដាច់កន្ទុយភ្នែក ជាប់

ជើងមេឃ ខ័ណ្ឌដោយកន្លែងខ្លះៗមានដើមឈើខ្ពស់ៗ គឺទីត្រង់នោះហើយជាវត្តអារាមរបស់ខ្មែរក្រោម ។ មានជួនកាល ដែលស្ទើរតែតិចតួចណាស់មិនសូវមានផង គេសង្កេតឃើញមានដើមត្នោត ដែលជាលក្ខណៈពិសេសសំរាប់សំគាល់នូវទេសភាពនៃវាលជនបទរបស់ខ្មែរ ។ ជួនកាលមានដើមព្រីងនៅតាមព្រៃល្បោះជាពិសេសដើមគគីរ ( le Koki ) ដែលពួកយួនហៅយ៉ូវ ( dau ) ប្រកបដោយដើមធំសំបើម ហើយត្រង់ៗភ្លីង ដែលគេទុកបំរុងនឹងយកទៅលុងធ្វើទូក-ង សំរាប់ប្រណាំងគ្នា ហើយដែលនៅតាមគ្រប់ភូមិខ្មែរ តែងតែមានទូកបែបនេះគ្រប់ៗភូមិ ។ ពីឆ្ងាយ កាលណាគេក្រឡេកឃើញដើរគគីរច្រើនដេរដាស់កំពស់ប្រហាក់ប្រហែ-លគ្នា ព្រោះដាំពេលជំណាលគ្នា ទីត្រង់នោះឯងហើយគឺវត្តអារាម ទោះបីជាផ្លាស់ប្តូរទៅឲ្យយួនសង់វត្តលោកយួនក៏ដោយ ក៏គេនៅតែរក្សាទុករុក្ខជាតិនេះដដែល ( បើគេកាប់មួយដើមធ្វើទូក គេដាំបន្តទៅទៀត ) ។ នៅពេលដែលចូលទៅដល់ទីនោះភ្លាម គេរមែងមានការចាប់អារម្មណ៍ទៅលើទីលានផ្ទៃដីដ៏ធំធេង ដ៏ល្វឹងល្វើយទូលំទូលាយ ហើយដែលនៅកណ្តាលទីធ្លានោះ មានព្រះវិហារតាំងនៅចន្លោះផ្លូវលំតូចៗ និងស្រះទឹក ។ នៅត្រង់នេះជាសាលាសំរាប់ប្រជុំពេលបុណ្យទានម្តងម្កាល ។ នៅត្រង់ណោះកុដិព្រះសង្ឃជាហូរហែរ សង់ខ្ពស់ផុតពីដីសំរាប់ធ្វើសម្មាធិសិល ។ មនោសញ្ចេតនាទូលំទូលាយ, រុក្ខជាតិជាជួរត្រង់ភ្លឹង រួមផ្សំនឹងទំនៀមទម្លាប់ប្រពៃណីប្រកបដោយសប្បុរសធម៌ថែមពីលើនោះទៀត បានចង្អុលបញ្ជាក់ប្រាប់ថា ទីនេះហើយជាកន្លែងសក្ការៈបូជា ហើយដែលមានលក្ខណៈខុសគ្នាស្រឡះពីព្រះវិហារយួនឬចិន ដែលសង់សឹងតែគរលើគ្នា-ជាប់ៗគ្នា ។ គេតែងរីករាយនិងគយគន់នូវស្ថាបត្យកម្មដ៏សមសួនទាំងនោះ ដោយទុកឲ្យមានខ្យល់អាកាសចេញចូលយ៉ាងបរិបូណ៌ ទោះបីក្នុងន័យទំហំ ក៏ដូចក្នុងន័យគំនូសបន្ទាត់ត្រង់ក្នុងលំហអាកាសផងដែរ ។ នេះជាការបញ្ជាក់ឲ្យឃើញថា ចាប់តាំងពីមានទំនាក់ទំនងជាដំបូងបង្អស់ ជាមួយអរិយធម៌អង្គរមកម្ល៉េះ បានជំរុញឲ្យគេមានស្មារតីភ្ញាក់រលឹកចាប់អារម្ម-ណ៍ទៅលើសោភ័ណភាព, ភាពសមសួន ត្រឹមត្រូវគ្នាទៅនឹងទំហំ ដែលសិល្បករពីអតិតកាលរមែងមានទស្សនៈខ្ពស់បំផុត ។ វត្តអារាមទាំងឡាយនៅដែនកូសាំងស៊ីនឥតមានលក្ខណៈអ្វីខុសប្លែកពីវត្តនៅប្រទេសកម្ពុជាសោះឡើយ ។

វត្តទាំងឡាយនោះឥតមានការប្រែប្រួលផ្លាស់ប្តូរអ្វីទាល់តែសោះ ពោលគឺគ្រប់ៗវត្តរមែងសង់នៅលើទីលានធំទូលាយ លើដីចាក់បំពេញយ៉ាងខ្ពស់ ធ្វើជាឿន២ ត្បាជាន់ (ព្រះវិហារ) ហើយហ៊ុំព័ទ្ធដោយកុដិ, សាលាឆាន់, សាលាឆទាន, កន្លែងធ្វើសម្មាធិ ប្រកបដោយដំបូលឬកំពូលច្រើនត្រួត និងមានក្បូរក្បាច់រចនាប្លែកៗគ្នាពីអាគារមួយទៅអាគារមួយទៀត ។ នៅគ្រប់មុមដំបូលនៃព្រះវិហារ មានលំអទៅ

ដោយរូបគ្រុឌ ឆ្លាក់ជាក្បាច់ដ៏ល្អប្លែក លាបពណ៌ទឹកមាស ឬក៏រូបចម្លាក់ផ្សេងៗប្លែកៗ ដែលភាគច្រើនៗតែនិយាយអំពីរឿងព្រះពុទ្ធ ដែលគេដកស្រង់ចេញពីគម្ពីរដីការស្តីពីពួកទមិឡអត់សាសនា អ្នកប្រឆាំងនឹងព្រះពុទ្ធ ។ ជួនកាលទៀត គេស្រង់យកចម្លាក់តាមបែបបទចិនមកលំអកំពូល ហើយបើយោងតាមលក្ខណៈបែប នេះជាការចង្អុលបញ្ជាក់ឲ្យឃើញច្បាស់ថែមទៀតថា យើងមិនមែននៅចំកណ្តាលប្រទេសកម្ពុជានោះឯណា ? (Nous ne sommes plus au Coeur du Cambodge ) តែជាកន្លែងសំរាប់ទាក់ទងគ្នាទៅវិញទៅមក ហើយដែលការចម្លងតាម ការធ្វើតាមវិស័យសិល្បៈ អាចធ្វើបានតាមចិត្តចង់ និងដោយអធ្យាស្រ័យទៀតផង ។

តែជាអកុសលគួរឲ្យស្តាយណាស់ ត្រង់ដែលថាការប្រើប្រាស់ជាតិស៊ីម៉ង់ត៍ បណ្តាលឲ្យមានផុំក្លិនអាក្រក់ពេកនៅតាមសំណង់នានាទាំងនោះដែលភាគខ្លះមានលក្ខណៈស្រស់ល្អប្រិមប្រិយ៍ ។ គ្រឿងចម្លាក់ក្បាច់ក្បូរធ្វើពីឈើសុទ្ធសាធ ប្រែត្រឡប់ទៅជាចាក់ពុម្ពក្បូរឲ្យព្រឺខ្លាច។ ខ្ញុំមិនដឹងថា តើខ្ញុំត្រូវធ្វើការទទូចតវ៉ាបញ្ជាក់យ៉ាងណាតទៅទៀតទេស្តីអំពីប្រយោជន៍ជាចាំបាច់ក្នុងការអប់រំសារឡើងវិញ នូវន័យនៃសោភ័ណភាព ( du sens esthétique ) ដែលជនជាតិខ្មែរមានកិរិតខ្ពស់ពន់ពេកណាស់ទៅហើយ ៗដែលត្រឡប់ទៅជាធ្វើឲ្យថោកតម្លៃទៅវិញ ( Avili ) នោះ ។ ចំពោះប្រជាជាតិមួយដែលតែងយកចិត្តទុកដាក់ ថែទាំគាំពារដូចជាប្រជាជាតិរបស់យើងនោះ ការធ្វើឲ្យភ្ញាក់រលឹកឡើងវិញ និងការពន្យល់ឲ្យខិតខំរក្សាឲ្យនៅគង់វង្សឲ្យយកចិត្តទុកដាក់និងថែទាំនូវគុណសម្បត្តិដ៏ល្អប្រពៃរបស់ប្រជាពលរដ្ឋនៅឥណ្ឌូចិន បើតាមខ្ញុំយល់ថាវាមិនមែនជាកិច្ចការដ៏ថ្លៃថ្នូរឡើយ។ ការខិតខំ ប្រឹងប្រែងយ៉ាងពេញទំហឹងបានចាត់ធ្វើហើយនៅភ្នំពេ ញ ដោយក្រុមសាជីវកម្មខ្មែរ ( អង្គការនៃអ្នកមានមុខរបរ ដូចគ្នា Les corporations Cambodgiennes ) ដឹកនាំ លោក George Groslier ។

ការចាប់កំណើតឡើងវិញយ៉ាងជាក់ស្តែង បានបង្ហា ញឲ្យឃើញយ៉ាងប្រត្យក្សពីការលូតលាស់ក្នុងវិស័យឧស្សាហកម្មតម្បាញ និងឧស្សាហកម្មផ្នែកសិល្បៈនៃការឆ្លៃធ្វើគ្រឿងមាស-ប្រាក់ (l'orfèvrerie) ។ ក៏ប៉ុន្តែ, កាលពីសម័យដើម នៅដែនកូសាំងស៊ីននេះ នាតំបន់ទ្រីតុង (ស្វាយទង) មានរោងតម្បាញតាមគ្រួសារ ដែលគេបាន ត្បាញសំពត់ឬក្រដាស់សំរាប់ពាសជញ្ជាំង (des tentures) នៅតាមវត្តអារាមនានា ប្រកបដោយក្បូរក្បាច់ល្អឆើត ។ សិល្បៈបែបនេះបានរលាយបាត់បង់អស់ទៅហើយ ដូចយើងបាត់បង់អស់រលីងនាពេលបច្ចុប្បន្ននេះ នូវអតិតស្ថាបត្យករ ( des anciens architectes ), អ្នកសាងចម្លាក់ក្បូរក្បាច់ ( des sculpteurs ) ហើយនិងជាងផាត់ពណ៌ឲ្យលេច (et des enlunineurs) ។ ប្រសិនបើគេអនុញ្ញាត

ឲ្យខ្ញុំបញ្ចេញសំណូមពរនាពេលនេះ គឺខ្ញុំសុំជាបន្ទាន់ឲ្យខ្មែរនៅដែកូសាំងស៊ីន មានសាលាសិល្បៈឬសាលារចនារបស់ខ្លួនមួយ ដូចជនជាតិយួនគេមានរបស់គេ នៅបៀង-វ៉ា, នៅធូ-យ៉ូវម៉ោក ( ទួលតាមោគ ) និងនៅ យ៉ា-ឌីញអញ្ជើង ។

នៅក្នុងវត្តអារាមទាំងនោះ សឹងតែគ្មានរបស់របរអ្វីគួរឲ្យកត់សំគាល់សោះទេ តែគេមានការចាប់អារម្មណ៍ភ្លាមមួយរំពេច ពេលដែលគេចូលទៅក្នុងបរិវេណវត្ត គឺមិនសូវជាមានគ្រឿងតុទូតាំង និងគ្រឿងលំអច្រើនឆើតឆាយលើយ មិនសំបូរបែបហូរហៀរស្មោកស្មុះដូចក្នុងវិហារយួនឬចិនទេ ។ មានតែកន្ទេល២-៣ក្រាលលាត សន្ធឹងផ្ទាល់នឹងកំរាលឥដ្ឋ សំរាប់ព្រះសង្ឃគង់សូត្រធម៌ ។ នៅខាងម្ខាងទៀតឯណោះ មាគ្រែសំរាប់ព្រះគ្រូចៅអធិការ ឬសំរាប់ព្រះសង្ឃដទៃទៀត គង់នៅពេលត្រូវវេនឡើងទេសនាម្តងៗ។ នៅលើបល្ល័ង្កដ៏កល់ព្រះពុទ្ធរូបសំខាន់ជាងគេ មានព្រះជីរយ៉ាងធំខ្ពស់ផុតគេឯង ហើយហ៊ុំព័ទ្ធជុំវិញដោយសាវ័កតំណាងព្រះអង្គជាច្រើនអង្គទៀតផង ហើយដែលមានទំហំធំតូចយ៉ាងសមសួន មានរូបរាងប្រហាក់ប្រហែលព្រះអង្គធំ ពោលគឺគេគ្រាន់តែចម្លងឆ្លាក់តាមគំរូដើមតែប៉ុណ្ណោះ ។ នៅតាមជញ្ជាំងព្រះវិហារដដែលហ្នឹង គេសង្កេតឃើញមានផ្ទាំងគំនូរគូរភ្ជាប់ទៅនឹងជញ្ជាំងតែម្តង នូវរឿងរ៉ាវស្តីពីជីវិតរស់នៅរបស់ព្រះបរមគ្រូព្រះសមគោត្តម ឬរឿងព្រេងដកស្រង់ចេញពីគម្ពីរមហាជាតក ឬរឿងរាមកេរ្តិ៍ ឬរឿងព្រះឥន្ទ, ព្រះព្រហ្មយមបាល ។ ចំពោះរឿងព្រះឥន្ទ គេអាចស្គាល់បានភ្លាមនូវតួអង្គព្រះឥន្ទ ដោយមានមុខខៀវ ។ ប្រជាពលរដ្ឋខ្មែរ ទោះនៅដែនកូសាំងស៊ីនក្តី ទោះនៅប្រទេសកម្ពុជាក្តី គេគ្រប់ៗរូបតែងគោរពព្រះពុទ្ធសាសនាផ្នែកហិនយាន ( Le Bouddhisme du Petit Véhicule ) ពោលគឺទ្រឹស្តី, ក្បួនខ្នាត, ក្បួនច្បាប់ដែលដកស្រង់ចេញពីគម្ពីរជាភាសាបាលី ហើយដែលមានឥទ្ធិពលគ្របដណ្តប់ទៅលើប្រទេសនានាក្នុងភូមិភាគប៉ែកខាងត្បូង មានប្រទេសសេរីលង្កា, សៀម និងភូមា...។ ការរៀនសូត្រខាងផ្លូវធម៌ ស្ថិតនៅជាប់ស្អិតទៅនឹងទំនៀមទំលាប់ជំនាន់ដើម ។ ក៏ប៉ុន្តែ ខ្ញុំត្រូវតែរៀបរាប់ជាបន្ថែមទៅទៀតថា ពុទ្ធនិយមបែបហិនយាននេះត្រូវបាននាំចូលមកក្នុងប្រទេសដោយជនជាតិថៃ តែត្រូវបានជ្រួតជ្រាបចូលមកក្នុងប្រទេសកម្ពុជា ក្នុងពេលកន្លងមកថ្មីៗនេះស្មោះតែម្តង ។

រីឯពុទ្ធនិយមបែបមហាយាន ( Le Bouddhisme du Grand Véhicule) នោះវិញ ប្រកបដោយក្បួនច្បាប់ទូលំទូលាយ មានទំនាក់ទំនងស្មុគស្មាញ បានសំរេចឲ្យមានលក្ខណៈយ៉ាងធំធេងដែលជាហេតុញ៉ាំងឲ្យមានទស្សនៈវិស័យផ្នែកសិល្បៈរាប់មិនអស់- បានជ្រួតជ្រាបប្រកបដោយឥទ្ធិពលនិងជំនឿយ៉ាងក្រាស់ក្រែល តាំងពីសម័យអង្គរមកម្លេះ ។

គេប្រាកដជាយល់ដោយការភ័ន្តច្រឡំជាមិនខានឡើយ ដែលថាទ្រឹស្តីសាសនា



រូបថតសាលាបាលីសមាគមខេត្តឃ្លាំង សង្កាត់៦ ទីរួមខេត្តឃ្លាំង ( ប្រទេសកម្ពុជាក្រោម ) <អង្គរបូរី> សូមថ្លែងអំណរព្រះគុណចំពោះព្រះតេជព្រះគុណ ថាច់-សារ៉ុង គង់នៅវត្តកាណាជា ដែលបានផ្ញើរូបថតវត្តអារាមខ្មែរក្រោមជាច្រើនមកទីចាត់ការរបស់យើងសំរាប់ចុះផ្សាយទុកជាឯកសារ ។

ក្បួនទូន្មានទាំងអម្បាលមាណក្នុងព្រះពុទ្ធសាសនា ដែលបានចាត់ចែងបង្រៀនឡើងដោយព្រះសង្ឃប្រកបដោយស្បង់ជីពរពណ៌លឿងទុំ (les bonzes à robe jaune)ទៅនោះជាការគ្រប់គ្រាន់ពេកណាស់ទៅហើយទៅតាមចំណង់ចំណូលចិត្តដល់ខ្មែរទាំងឡាយដែលមានជំនឿស៊ប់ទាំងអស់នោះ ឲ្យសប្បាយរីករាយចូលចិត្ត។ មុននឹងចាកចេញពីវត្តអារាមនិមួយៗ យើងតោងដើរសំដៅទៅជ្រុងខាងជើងឆៀងខាងកើត ( ទិសឦសាន ) នៃរបងព័ទ្ធជុំវិញវត្ត យើងរមែងតែងតែប្រទះឃើញជានិច្ចជាកាល នូវរានខ្ទមជំរកដ៏សាមញ្ញមួយធ្វើអំបីបន្ទះក្តារឬបន្ទះឫស្សី ដំឲ្យសំប៉ែត ដំបូលប្រក់ស្លឹកចាកឬប្រក់ក្បឿង... ទីនោះគឺជាវិមានរបស់ «អ្នកតា» ដែលជាអ្នកផ្តល់នូវគំនិត ជួនកាលល្អជួនកាលកាចសាហាវឃោរឃៅ ហើយដែលរូបភាពតំណាង«អ្នកតា»នោះ ជាទូទៅច្រើនតំណាងដោយដុំថ្ម២-៣ដុំគ្មានរាងរៅអ្វីទេ ហើយនៅខាងមុខដុំថ្មទាំងនោះ គេតែងសង្កេតឃើញផេះធូបដែលរលត់ទៅហើយ បន្ទាប់ពីពេល

គេដុតសែនថ្វាយបង់ស្រន់រួចមក ត្រូវខ្យល់បក់ផាត់ហើរអារាត់អារាយពាសពេញ។
នៅក្នុងចំណោមប្រជាកសិករទាំងឡាយ ទោះបីខ្មែរឬយួនក៏ដោយ គេរមែងមានជំ
នឿទៅលើអារក្សអ្នកតាណាស់ ។ ខ្មែរនៅដែនកូសាំងស៊ីន ក៏ដូចជាជនរួមឈាមរប
ស់ខ្លួននៅប្រទេសកម្ពុជាដូច្នោះដែរតែងខ្លាចរអារទៅលើអំពើរអាក្រក់អាក្រីដែលមើ
លមិនឃើញទាំងនោះខ្លាំងណាស់ ដូចជាអារុក្ខ អារក្ស អ្នកតា មេមុត បង់បថគ្រូធ្មប់
គ្រូវេទមន្តដែលគេតែងហៅអញ្ជើញឲ្យមកជួយសំរាលទុក្ខ សំរាលកំហឹងរបស់គេ។
អបិយជំនឿ ( ការជឿផ្តេសផ្តាស់ ) បែបនេះទៅលើវត្ថុធាតុដែលមើលមិនឃើញ
ហើយដែលសុទ្ធសឹងជាអតិតតួអង្គព្រះអាទិទេពដ៏ល្អឥតខ្ចោះ អាចមើលឃើញធ្លុះ-
នៅក្នុងព្រហ្មញ្ញសាសនាតែដែលមកដល់ពេលបច្ចុប្បន្ន បានសាបរលាបរលត់រលា
យស្ទើរអស់ទៅហើយ។ ហេតុដូច្នេះហើយ បានជាព្រះនាងខ្មៅ (la Dame Noire )
ជាភាសាយួនBà Dèn បានត្រូវគេឲ្យទៅឈ្មោះភ្នំមួយនៅក្នុងខេត្តតៃនិញ- នេះគ្មាន
អ្វីក្រៅនាងកាឡី ដែលឈ្មោះនេះគេរុករកឃើញឡើងវិញ នៅក្នុងពាក្យកាល់គុត្តា
Calcutta- តំណាងអាទិទេពធ្វើអំពើល្អ ឬក៏កាចសាហាវឃោរឃៅ ដែលជាអ្នកទទួ
លខុសត្រូវ ចំពោះការឈឺចាប់ទាំងអម្បាលមាណ ដែលរមែងតែងតែកើតមានឡើ
ងក្នុងបណ្តាកូនក្មេងស្គាំងស្គមទាំងឡាយ ។

នៅគ្រប់ទីជនបទទាំងអស់សុទ្ធសឹងតែមានវត្ថុមានផ្ទៃរូបភាពតំណាងគំនិតមិន
ចេះនិយាយទាំងនេះ ដែលគេតែងតាំងដំកល់នៅតាមវាលជនបទ ភាគច្រើនៗនៅ
ត្រង់ផ្លូវកោងបត់បែន នៅតាមភ្លឺស្រែឬក៏នៅក្បែរគល់ឈើធំៗ ។ ជាប្រចាំរៀងរាល់
ថ្ងៃ គេត្រូវប្រុងប្រយ័ត្នធ្វើយ៉ាងណា កុំឲ្យ « អច្ឆរិយវត្ថុ » ទាំងនោះមានកំហឹងក្រេវ
ក្រោធឆេះឆាបសោះឡើយ។ ជារឿយៗ ដើម្បីចង់ដឹងចង់យល់ចំពោះខ្ញុំ ៗរមែងទៅ
ចូលរួមជាមួយពួកគេ ដោយខិតខំរក្សាចិត្តគំនិត ដោយការប្រុងប្រយ័ត្នមុននឹងធ្វើអ្វី
ម៉្យាងៗ។ ទោះបីនៅចុងកាត់មាត់ញកឯណាក៏ដោយ លើដែនដីកូសាំងស៊ីនតាំងមូ-
ល ក្រោមនាមថា Ông Ta តែងមានមុខនាទីដ៏ល្បីធំសំបើមណាស់ ក្នុងជំនឿស៊ប់
របស់កសិករអ្នកស្រែចំការយួន ។ ការនេះហើតដែលនាំឲ្យខ្ញុំចាប់អារម្មណ៍ ។ មាន
ព្រឹត្តិការណ៍ប្លែកគួរឲ្យចាប់ចិត្តពីរស្តីពីមុខងារដ៏សែនមានន័យរបស់អារក្សអ្នកតាទាំ
ងនោះ ។ នៅពេលមួយ ខ្ញុំបានរៀបចំដឹកនាំយករូបចម្លាក់លឹង្គ ធ្វើពីថ្មម៉្យាងសំរាប់
សំណង់ (un grand Linga en grés) ដ៏ធំទម្ងន់ដល់ទៅកន្លះតោនឯណោះ ចង់យក
ទៅដំកល់ទុកនៅក្នុងសារមន្ទីរដែនកូសាំងស៊ីន ហើយលឹង្គនោះឯងបានឮល្បីល្បា
ញថា ជាតំណាង «អ្នកតាចិត្តអាក្រក់ចង្រៃបំផុត» ។ សរណវត្ថុ ( រូបសំរាប់គោរពបូ
ជា ) ស្ថិតនៅត្រង់កន្លែងមួយមានភក់ជ្រាំនិងដីសើមជានិច្ច ហើយស្ថិតនៅក្នុងការ
អស់សង្ឃឹម ប្រាកដរលត់រលាយរូបបាត់បង់ជាពុំខាននាពេលអនាគតយូរអង្វែងទេ



Photo: Thach Xe

នេះជារូបភាពព្រះវិហារវត្តតាមុំកំពុងកសាងឡើងវិញ បន្ទាប់ពីសង្គ្រាមនៅយៀកណាមខាងត្បូងបានរលត់ហើយ របបសាធារណរដ្ឋធីវ-គី ត្រូវបរាជ័យ ។ ក្នុងសម័យសង្គ្រាម១៩៦០-៧៥ ពួករបបសេរីក៏ដូចរបបកុម្មុយនិស្តសព្វថ្ងៃបានតាំងមូលដ្ឋានទ័ពទ័ពនៅក្នុងវត្តតាមុំ ហើយឆ្លៀតពេលហ្នឹង ពួកគេបានបាញ់ផ្លោងកាំភ្លើងកាណុងចូលក្នុងវត្ត បំណងដើម្បីកំទេចវត្តអារាមខ្មែរក្រោម ។ ដោយឃើញព្រះវិហារបាក់បែកខ្ទូចខាត ញាតិញោមពុទ្ធបរិស័ទរួមជាមួយគណៈវត្ត បានរៀបចំជួសជុលកសាងព្រះវិហារឡើងវិញ ទុកសំរាប់ប្រគេនព្រះភិក្ខុសង្ឃធ្វើវត្តបដិវត្តិន៍ និងសង្ឃកម្មនានា ។ វត្តតាមុំ ឃុំតាមុំ ស្រុកអង្ស៊ៀង ខេត្តក្រមួនស ប្រទេសកម្ពុជាក្រោម ។ យួនខំហៅតាមខ្មែរថា Giong Rieng ដែលក្លាយមកពីអង្ស៊ៀង ។

ដើម្បីធ្វើកិច្ចការនេះឲ្យបានសំរេច ខ្ញុំគោងដឹកនាំរូប «លឹង្គ» ឲ្យទៅដល់មាត់ព្រែក ដើម្បីនាំទៅតាមផ្លូវទឹកចុះរហូតទៅដល់ក្រុងព្រៃនគរ។ គេពិបាកនឹងប្រើរទេះគោក្របីណាស់ ព្រោះវាធ្ងន់ពេក។ ហេតុនេះហើយ ខ្ញុំក៏អំពាវនាវហៅរករទេះម៉្យាងសំរាប់រំអិលលើទឹកព្រែក (un traîneau) ដែលគេផ្ទឹមដោយគោ ។ ក៏ប៉ុន្តែទៅមុខបានប្រមាណ១០០ម៉ែត្រ ស្រាប់តែគោទាំងនោះក្រាញលែងដើរទៅមុខសោះតែម្តង ។ គេក៏ទៅយកក្របីមកផ្ទឹមជំនួសវិញ ក្របីមាឌមាំៗទាំងនោះក៏ក្រាញមិនដើរទៅមុខដូចគោដែរ ។ ដោយយល់ឃើញថាអ្នកតាដ៏សំបើមគួរព្រឺខ្លាច បើសិនណាខ្ញុំមិនអាចរកមធ្យោបាយធ្វើយ៉ាងណានាំដុំថ្មដ៏សែនចចេសរឹងរុះចេញពីទីនេះបានទេនោះ កេរ្តិ៍ឈ្មោះខ្ញុំប្រាកដជាសាបរលាបជាពុំខាន។ ដូច្នេះខ្ញុំក៏ចាត់ចែងឲ្យធ្វើជាស្នែងសែងរំកិលដោយមនុស្ស២០នាក់ ។ យើងក៏បានសំរេចជោគជ័យនាំ«អ្នកតា»ទៅដល់ភូមិ ក៏ប៉ុន្តែគ្មាននរណាម្នាក់យល់ព្រមយក«អ្នកតា»នោះទៅដាក់នៅជិតផ្ទះសំបែងរបស់គេសោះឡើយ ។ ខ្ញុំក៏សំរេចឲ្យគេយកទៅដឹកលទុកមុខសាលាឃុំ ដែលជាទីកន្លែងខ្ញុំរស់នៅ ដោយដាក់រ៉បបណ្តោយតាមផ្លូវលំចូល ។ គេក៏នាំគ្នារៀបដាក់ទទឹងផ្លូវ បន្ទាប់មកខ្ញុំក៏ចាត់ឲ្យរៀបស្របនឹងផ្លូវចូលឡើងវិញ ក្រោយមកពួកគេនៅតែចចេសទាញមកដាក់ទទឹងផ្លូវដដែល ។ ដោយខ្ញុំជជីកសួររកហេតុផលដែលបណ្តាលនាំឲ្យពួកគេមានៈចចេសខុសទម្លាប់ ចំឡែកខុសពីសព្វដងបែបនេះ គេក៏បានពន្យល់មកខ្ញុំវិញថា ៖ ក្នុងករណីទី១ ខ្លួនខ្ញុំផ្ទាល់នឹងត្រូវជម្ងឺអ្វីមួយមកយាយីបៀតបៀនជាពុំខាន ដោយការសំដែងនូវក្តីក្តៅក្រហាយមួម៉ៅរបស់អារក្សអ្នកតា ។ ចំណែកខាងលើកទី២វិញ ខ្ញុំចាត់ទុកថា ទង្វើបែបនេះជាការផ្ទុយឬល្មើសពីបញ្ជារបស់ខ្ញុំ ក៏ព្រោះតែគេចង់ការពារផលប្រយោជន៍និងក្តីសុខសប្បាយដល់រូបខ្ញុំផងដែរ ។ ប៉ុន្តែបើប្រសិនណាជាខ្ញុំមិនត្រូវការនូវការគាំទ្រការពារ គេក៏មិនអាចធ្វើឲ្យសំរេចបានដែរ ដោយបោះបង់ចោលឲ្យខ្ញុំទទួលទៅតាមវាសនាអាក្រក់ឧបទ្រពចង្រៃ វិនាសហិនហោចតាមយថាកម្មទៅចុះ ។ បន្ទាប់ពីពេលនោះមក ខ្ញុំក៏បានទៅពិនិត្យដីទួលដំបូកមួយកន្លែង ដែលខ្ញុំបានចាត់ចែងជីកកកាយរុករកក្នុងដីនូវបុរាណវត្ថុ ។ នៅលើកំពូលនៃដីដំបូកនេះ ហើយនៅត្រង់គល់ឈើមួយដើមធំ មានផ្ទាំងថ្មម៉្យាងរឹងបំផុត ( un bloc de granit) គ្មានរាងរៅឥតទ្រង់ទ្រាយអ្វីទេ ដែលគេជឿជាក់ថា មានព្រលឹងខ្មោចព្រាយអ្នកតាអារក្ស ប្រកបដោយកំហឹងឃ្នានិស តាមបំផ្លាញដោយក្តីមួម៉ៅក្តៅក្រហាយ ហើយដែលអ្នកស្រុកទូទៅក្នុងតំបន់នោះបានដឹងច្បាស់គ្រប់ៗគ្នា ។ ខ្ញុំក៏ចេញបង្គាប់បញ្ជាមិនឲ្យនរណារំកិលផ្ទាំងថ្មនេះចេញពីទីនោះជាដាច់ខាត ដើម្បីចៀសវាងជាចាំបាច់ក្នុងការរក្សានូវសេចក្តីសុខសប្បាយដល់ពពួកកម្មករគូលីទាំងឡាយ ។ នាថ្ងៃដដែលហ្នឹង ខ្ញុំក៏ប្រទះឃើញនៅលើដីទួលដំបូកនោះផងដែរ នូវមនុស្សបីនាក់ដែល

កំពុងរៀបចំបន់ស្រន់ថ្វាយដង្វាយដល់អ្នកតា ។ ពួកគេទើបនឹងរៀបចំនៅទីសក្ការៈបូជានាទីជនបទស្រុកស្រែចំការនេះនូវ ៖ទាខ្វៃមួយ, ស្រាសមួយដប, ផ្លែឈើខ្លះៗ, បាយមួយចាន ហើយនិងធូបមួយដុំ ។ ពេលនោះពួកគេក៏ក្រោកឈរឡើង រៀបចំចាកចេញពីទីនោះ រួចពួកគេក៏បាននិយាយរ៉ាយរ៉ាប់ប្រាប់ខ្ញុំថា នាថ្ងៃមួយឪពុករបស់ពួកគេបានទៅមើលកិច្ចការដែលខ្ញុំបានចាត់ចែងឡើងនោះ ( ការរំកិលអ្នកតាមហាលិង្គ) គាត់ក៏ស្រាប់តែឈឺចុកចាប់ធ្វើទុក្ខបុកម្នេញ កើតមានឡើងភ្លាមមួយរំពេចហើយមិនទាន់ឃើញមានការជាសះស្បើយនៅឡើយ ។ នោះប្រាកដជាអ្នកតាចាប់កំហុសចាប់ទោសអួសដំណើរយ៉ាងកាចសាហាវ យ៉ាងអាក្រក់អាក្រីដោយពិតប្រាកដហើយ ។ ដល់វេនខ្ញុំមកដល់ហើយ ខ្ញុំក៏វិលត្រឡប់ទៅកាន់ទីនោះសារឡើងវិញដោយមានជនជាតិខ្មែរម្នាក់មានថាច់-វង្ស បានទៅជាមួយខ្ញុំផងដែរ រួចគាត់បានសុំអនុញ្ញាតពីខ្ញុំ ឲ្យគាត់សុំប្តឹងតវ៉ាចំពោះសារណាវត្ថុនោះផង ។ ខ្ញុំឃើញគាត់និយាយតវ៉ាដោយការខ្សិបខ្សៀវយ៉ាងយូរវែងអន្លាយជាមួយថ្មអ្នកតានោះ។ គាត់និយាយទៅរកអ្នកតាដោយសម្លេងតិចៗ ប្រកបដោយវាចានិងកាយវិការបញ្ចុះបញ្ចូលឲ្យជឿជាក់មកលើរូបគាត់ ។ គាត់ពន្យល់ទៅអ្នកតាថា រូបគាត់ថាច់-វង្សជាជនកូនចៅក្រីក្រលំបាកណាស់ ហើយគាត់មានការស្រេកឃ្លានជាពន់ពេក ។ ចំណែកខាងអ្នកតាដ៏មានឥទ្ធិឫទ្ធិដោយការភ័យខ្លាច និងដោយការគោរពបូជាពីសំណាក់សាធារណជនទូទៅ អ្នកតាមានអ្វីៗសព្វបែបយ៉ាងសំបូរហូរហៀរឥតខ្វះ ។ ដូច្នេះហើយ គាត់ក៏តាំងស្នើសុំដោយក្តីគោរពឱនលំទោន សុំអ្នកតាមេត្តាចែករំលែកនូវគ្រឿងបូជាទាំងអំបាលម្យាណដែលសប្បុរស ជនបាននាំយកមកថ្វាយនោះឲ្យដល់រូបគាត់ផងដោយក្តីអនុគ្រោះ ។ ខ្ញុំសន្និដ្ឋានថា ប្រហែលជាអ្នកតាយល់ព្រមតាមសេចក្តីស្នើសុំរបស់របស់ថាច់-វង្សនោះហើយ បានជាខ្ញុំឃើញគាត់លើកដបស្រា-សធឹកក្អឹកៗ កាច់ជើងទានិងកទាទុកឲ្យអ្នកតាដោយជឿស៊ុប ហើយរបស់របរក្រៅពីនោះគាត់ប្រមូលយកខ្ទេច ។ រឿងរ៉ាវពីអ្នកតានេះ បង្ហាញបញ្ជាក់ប្រាប់យើងឲ្យដឹង ពីសតិសម្បជញ្ញៈដ៏ធម្មតាងាយយល់បំផុតចំពោះប្រជាកសិករខ្មែរ ក៏ដូចជនជាតិភាគច្រើនដូច្នោះដែរពោលគឺត្រឹមតែសុំប្រកបរបរកសិកម្ម ដោយសុខសប្បាយតែប៉ុណ្ណោះ ។ ពួកគេម្នាក់ៗ ទោះបីខ្មែរឬយួនក៏ដោយ មានឫកពារចរិយាគួរឲ្យស្រឡាញ់រាប់អាន និងគួរឲ្យគោរពយកចិត្តទុកដាក់ទៀតផង ។ នៅពេលណាដែលគេនិយាយអំពីការរស់នៅយ៉ាងធម្មតា យ៉ាងសាមញ្ញបំផុតរបស់ពួកគេវិញ ពួកគេតែងនាំគ្នាអង្គុយលើកន្ទេលផឹកតែជជែកពីរឿងផ្សេងៗដោយស្មោះត្រង់ ដោយគ្មានកល្បល្បិច ។ ឯអ្នកស្តាប់ក៏

ប្រុងត្រចៀកស្តាប់ដោយក្តីរីករាយ និងដោយការយកចិត្តទុកដាក់ ។ ត្រង់នេះខ្ញុំសង្កេតឃើញដោយជឿងឆ្ងល់ដោយក្តីចម្លែកថា ពួកគេទាំងឡាយនោះមានលក្ខណៈមិនខុសគ្នាទាល់តែសោះ នឹងកសិករនៅតាមជនបទជិតឆ្ងាយនាប្រទេសបារាំងរបស់យើង ហាក់បីដូចជាពួកគេបានថ្លឹងពិចារណារួចជាស្រេច ដោយឥតមានការសង្ស័យក្នុងការបង្ហាញនូវអមិត្តភាព នូវការប្រទូស្តរាយចំពោះជនជាតិបរទេសសោះឡើយ ។ ជាច្រើនលើកច្រើនដងណាស់មកហើយ ដែលខ្ញុំរមែងធ្វើដំណើរសព្វទិសទី ដើរ ជិះសេះ ជិះរទេះ ឬជិះសំប៉ានទៅ គ្រប់ខេត្តខ័ណ្ឌទាំងឡាយនៃដែនដីកូសាំងស៊ីនដោយព្រមទទួលតាមសេចក្តីអញ្ជើញដ៏ស្មោះស្ម័គ្រពីវត្តអារាមនានារបស់ខ្មែរ ។




រូបថតព្រះវិហារវត្តនិគ្រោធ កំពង់ក្សាន្ត ខេត្តព្រះត្រពាំង ( ប្រទេសកម្ពុជាក្រោម

ពួកគេប្រញាប់ប្រញាល់រត់រកបេះផ្លែដូងខ្ចីយកមកឲ្យខ្ញុំផឹក ដើម្បីបំបាត់ការស្រេក ។ ចំណែកខាងខ្ញុំវិញ ខ្ញុំបានជូនដល់ពួកគេនូវទៀនធូបនិងកញ្ចប់តែ។ ក្នុងផ្ទះជនដែលទទួលឲ្យខ្ញុំស្នាក់អាស្រ័យ គេក្រាលកន្ទេលទទួលខ្ញុំសំរាន្តសំរាកកាយ ។ នារដូវក្តៅពេលថ្ងៃត្រង់ក្តៅខ្លាំង ប្រកបដោយវាយោដ៏បរិសុទ្ធបក់រំភើយៗមកម្តងម្កាល ខ្ញុំហា

ក់ដូចជាមានអារម្មណ៍ ថាគ្មានពេលណាហើយដែលស្ងប់ស្ងាត់ក្នុងសតិអារម្មណ៍ជាជាងពេលនេះទេ ។ ខ្ញុំគេងទំរេតលើគ្រែទំរេតធ្វើអំពីឫស្សីនៅលើផ្ទះខ្មែរទាំងនោះសង់ខ្ពស់ពីដី ។ ខ្ញុំសង្កេតមើលព្រះសង្ឃប្រកបដោយស្បង់ជីពរពណ៌លឿងទុំ កំពុងនិមន្តដោយស្រូតគត់ស្រគំនៅតាមទីធ្លា... ម្តងៗខ្យល់រំភើយតិចៗបានបោកបក់យោលកញ្ចុំផាងដូងវរិចៗ ។ ជាញយដង ខ្ញុំតែងទៅកាន់សាលារៀននៅតាមវត្តនានានៅពេលក្មេងៗចេញលេងម្តងៗ ដោយឮសម្លេងជជែកគ្នារអ៊ូៗតិចៗ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍នឹកឃើញថា នៅទីនេះបញ្ហាសិក្សាធិការបានចោទយ៉ាងខ្លាំងណាស់ទេតើ ចំពោះសហគមជនជាតិភាគតិចខ្មែរនៅដែនដីកូសាំងស៊ីននេះ! ។ សហគមខ្មែរនេះមានលក្ខណ:ដូចគ្នាទាំងអស់ (un ensemble homogène) ទាំងចិត្តគំនិតទាំងទម្លាប់រស់នៅ ទាំងភាសា ទាំងសាសនា ទាំងទំនៀមទំលាប់ ទាំងប្រពៃណី...។ ដោយតាំងចិត្តយ៉ាងខ្ជាប់ខ្ជួនក្នុងកិច្ចថែរក្សានូវទំនៀមទម្លាប់របស់ពួកគេយ៉ាងម៉ឺងម៉ាត់នោះម្ល៉ោះហើយពួកគេស្ទប់ខ្ពើមមិនចង់បញ្ជូនបុត្រធីតារបស់ពួកគេទៅកាន់សាលារៀនបារាំង-យួន (Ecole Franco-Annamite) ទោះបីភាសាបារាំង-ខ្មែរ (Ecole Franco-Khmère) មានចំនួនតិចតួចក៏ដោយ ។ រហូតមកដល់ពេលនេះ គេបានសាកល្បងរិះរកមធ្យោបាយដោយលំបាកក្នុងកិច្ចញ៉ាំងឲ្យសិក្សាធិការសម័យបុរាណបានជឿនលឿនចំរើនលូតលាស់ តាមរយៈសាលារៀននៅតាមវត្តវាំ ។ សាលាវត្តមានបីបែប ៖ សាលាវត្តបែបទីមួយជាសាលាស្វ័យភាព (ឯករាជម្ចាស់ការខ្លួនទីពឹងខ្លួន) ដូច្នេះសាលារៀនបែបនេះ ឥតនៅក្រោមអាណាព្យាបាលរបស់យើងឡើយ ។ សាលាបែបនេះគេរាប់ទៅឃើញមាន៩៥សាលាក្នុងឆ្នាំ១៩៤៤ ដោយមានសិស្សានុ-សិស្សសរុប១០៥៨នាក់ ។ សាលាខ្លះទៀតត្រូវបានជំនួយឧបត្ថម្ភជាប្រាក់កាសនិងជាសម្ភារ:ពីរដ្ឋអំណាច ។ សាលាផ្នែកនេះមានចំនួន២០នាដើមឆ្នាំ១៩៤៥ ដោយ-មានសិស្សានុសិស្ស៥៧១នាក់។ នៅទីបញ្ចប់ ចាប់តាំងពីរវាង១៥ឆ្នាំកន្លងមកហើយគេបានខ្នះខ្នែងបង្កើតចំនួនសាលារៀននៅតាមវត្តអារាមនានា ដែលគេឲ្យឈ្មោះថា «សាលាវត្តទំនើបថ្មី Ecoles Pagodes Rénovées » ដែលកិច្ចការសិក្សាត្រូវបានព្រះសង្ឃជាអ្នកផ្តល់ឲ្យ ហើយដែលព្រះសង្ឃទាំងនោះ ត្រូវបានគេបញ្ជូនឲ្យនិមន្តទៅធ្វើកម្មសិក្សាក្រិតតែល្អប្រសើរ ( un stage de perfectionnement ) នៅទីក្រុងភ្នំពេញ, នៅខេត្តត្រាវិញ ឬនៅខេត្តសុកត្រាំង ។ ត្រង់នេះគេគោងខិតខំណែនាំផ្តល់យោបល់តាមកាលៈទេសៈដែលអាចធ្វើ ទៅបានតាមច្បាប់ ចំពោះសិក្សាធិការដែ-លមានលក្ខណៈស្មើរសុទ្ធសឹងតាមមាគ៌ា សាសនាតែទាំងអស់ទៅហើយនោះ ។ ចំនួនសាលារៀនបែបនេះបានកើនឡើងពី ៣៧ក្នុងឆ្នាំ១៩៣០ ទៅដល់៩០ក្នុងឆ្នាំ១៩-៣៦ ហើយនិងមានរហូតទៅដល់២០៩ក្នុ ងឆ្នាំ១៩៤៤ ។ រីឯចំនួនកូនសិស្សក៏បាន

កើនឡើងជាលំដាប់លំដោយដែរ គឺពី១៥ ២៨នាក់ក្នុងឆ្នាំ១៩៣០ រហូតទៅដល់៧២-៧៤នាក់ក្នុងឆ្នាំ១៩៤៤ ។ ក្នុងចំណោមនោះ គេរាប់ឃើញមានសិស្សនារី១០៩៣នាក់ដែរ ដែលរហូតមកទល់ពេលនេះ សិស្សស្រីៗដោយសំអាងទៅលើទំនៀមទំលាប់ប្រពៃណី ត្រូវគេធ្វើឲ្យឃ្លាតឆ្ងាយពីការសិក្សា ។ នៅក្នុងដំណាលពេលជាមួយគ្នានោះ ចំនួនសាលារៀនបារាំង-ខ្មែរ ( Ecoles Officielles Franco-Khmères ) ជាផ្លូវការក៏មានមិនលើសពី១៩សាលាដែរ ហើយមានគ្រូបង្រៀនតែ៣០នាក់ប៉ុណ្ណោះ ។ ត្រង់នេះវាមានបញ្ហាមួយដែលគួរតែចងចាំក្នុងសតិអារម្មណ៍ ។ ទោះបីមានការចាត់ចែងឲ្យមានការអប់រំព្រះសង្ឃជាគ្រូបង្រៀនយ៉ាងនោះក៏ដោយ ក៏ការបង្កើត « សាលាវត្តបែបថ្មី Ecoles de pagodes Rénovées » នោះគ្រាន់តែជាមធ្យោបាយបណ្ដោះអាសន្នតែប៉ុណ្ណោះ ក៏មិនអាចជាជំនួសការសិក្សាធម្មតា ដែលមានពីរផ្នែកនោះឡើយ គឺផ្នែក ( Cycle Elémentaire : កុមារដ្ឋាន, បរិវេចនដ្ឋាន និង អាទិកដ្ឋាន ) ដែលការសិក្សាស្ថិតនៅជាភាសាខ្មែរ ។ ឯផ្នែក ( Cycle Complémentaire :មជ្ឈិមដ្ឋានទី១, មជ្ឈិមដ្ឋានទី២ និង ឧត្តមដ្ឋាន ) នោះវិញ គោងចាប់ផ្ដើមឲ្យស្គាល់ចេះអក្សរសាស្ត្រជាភាសាបារាំង ។ ក៏ប៉ុន្តែគេជួបប្រទះនឹង បញ្ហាពិបាកក្នុងការជ្រើសរើសរកគ្រូបង្រៀនបឋមសិក្សា ព្រមទាំងកិច្ចខិតខំខ្វះខ្វែង ដើម្បីបញ្ចូលការសិក្សាទៅក្នុងអាណាខេត្តទាំងឡាយរបស់ខ្មែរ (សង្គមខ្មែរសម័យបូរាណ) ។ ទាំងនេះហើយដែលធ្វើឲ្យគាំងដំណើរ ព្រោះតែកង្វះចំនួនគ្រូ ហើយនិងបុគ្គលិកមានសមត្ថភាព ។ ក្នុងន័យនេះ ខ្ញុំចង់ជំរុញសិក្សាធិការឲ្យជឿនលឿនទៅមុខ សំរាប់ជនជាតិខ្មែរនៅដែនកូសាំងស៊ីន ។ ហេតុនោះហើយបានជាចង់ឲ្យបឋមសិក្សាជាន់ដំបូង ( Ecoles Primaires Elémentaires) បានលូតលាស់ជឿនលឿនទៅមុខយ៉ាងឆាប់រហ័ស ជាហេតុញ៉ាំងឲ្យកូនខ្មែរទាំងឡាយមានវិញ្ញាបនប័ត្រ (Certificates d'Etudes) ហើយដែលពួកគេភាគខ្លះនឹងក្លាយខ្លួនទៅជាគ្រូបឋមសិក្សាជំនួយ ( Instituteurs auxiliaires ) រួចខ្លះទៀតនឹងក្លាយទៅជាគរុសិស្សជំនាន់ដំបូងបង្អស់នៅសាលាគរុវិជ្ជា ហើយដែលពួកគេត្រូវតែវិលត្រឡប់មកបំរើការងារផ្នែកសិក្សាធិការវិញពេលកិច្ចការអប់រំចប់សព្វគ្រប់រួចរាល់អស់ហើយ ដោយលះបង់ចោលផ្នែកកិច្ចការនយោបាយចេញ ដើម្បីចូលប្រឡូកជួយជំរុញការសិក្សាផ្នែកបឋមសិក្សា ដែលត្រូវចុះឱនថយយ៉ាងខ្លាំងនៅលើដែនដីឥណ្ឌូចិនទាំងមូល ចាប់តាំងពីមានវិបត្តិសេដ្ឋកិច្ចក្នុងរវាងឆ្នាំ១៩២៩-១៩៣៣នោះមក ។

បញ្ហាមិនត្រឹមតែទាក់ទងដោយផ្ទាល់ ឬប៉ះពាល់ជាពិសេសទៅដល់បុត្រាបុត្រីខ្មែរនៅដែនកូសាំងស៊ីន ក្នុងកិច្ចផ្ដល់នូវការសិក្សាផ្នែកបឋមសិក្សា ដែលជាសិទ្ធិរបស់ពួកគេប៉ុណ្ណោះឡើយ តែវាជាប់ទាក់ទងទាំងមូល ទៅនឹងបញ្ហាដ៏លំបាកក្នុងការ




រូបថតព្រះវិហារវត្តពោធិស្រះស្រង់ កំពង់ ( រកាថ្មី ) ( ប្រទេសកម្ពុជាក្រោម )

ជ្រើសរើសរកអ្នកចំណាននៗលើសគេ ( les élites ) ទៅទៀតផង ក្នុងចំណោមជនជាតិភាគតិចខ្មែរនៅត្រង់តំបន់ទន្លេមេគង្គផ្នែកខាងក្រោម (Bas-Mékong) ក៏ដូចជានៅប្រទេសកម្ពុជាទាំងមូលផងដែរ ។ ការដែលធ្វើឲ្យអ្នកសង្កេតការណ៍ចាប់អារម្មណ៍ជាងគេនោះ គឺថាក្នុងសង្គមនេះខ្វះយ៉ាងខ្លាំងនូវក្រុមបណ្ឌិតអ្នកដឹកនាំលើកលែងតែព្រះសង្ឃចេញ ។ នៅក្នុងរាជាណាចក្រខ្មែរសម័យបូរាណ ភាគច្រើនៗតែជនជាតិយួនទេ ដែលជាមន្ត្រីនៅក្នុងផ្នែករដ្ឋបាល ឬក្នុងផ្នែកកិច្ចការសាធារណៈ ហើយស្ថានភាពបែបនេះគឺចំពោះជនជាតិខ្មែរដែលត្រូវតែព្រួយបារម្ភជាងគេបង្អស់ តែហាក់បីដូចជាមិនទាន់មានការភ្ញាក់ផ្អើល ឬមានប្រតិកម្មតទល់ច្រើនណាស់ណាតែសោះ ។ នេះក៏ប្រហែលជាមានប្រភពដើមពីយូរវែងអន្លង់មកហើយក៏មិនដឹង ។ គួរកត់សំគាល់ថា ការចុះឱនថយនៃប្រទេសនេះ កើតមានឡើងនៅពេលដំណាលគ្នា នឹងសម័យកាលមួយដែលប្រទេសឥណ្ឌាត្រូវឃ្លានពានលុកលុយ ពីពួកម៉ុ-

យស៊ុលម៉ង់ (Invasions musulmanes អ្នកកាន់សាសនាមហាម៉ាត់) ។ ចាប់តាំងពីពេលដែលប្រទេសកម្ពុជាត្រូវខ្វះអ្នកក្រុមខណ្ឌដឹកនាំ ប្រហែលត្រូវផ្តល់ឲ្យដោយពពួកព្រាហ្មណ៍នោះឯងហើយ ដែលភាពអាប់ឱនក៏ត្រូវធ្លាក់ចុះចាប់ផ្តើមឡើងភ្លាម ។ មានមូលហេតុខ្លះៗដែរសំរាប់យកមកផ្សះផ្សារបីទបាំងការខ្វះខាតក្នុងកិច្ចជ្រើសរើសរកអ្នកចំណានជាងគេនោះដោយបានផ្តល់នូវហេតុផលដូចគ្នានាសម័យហ្វូណនបូរាណ (dans l'ancien Fou-nan) ហើយដែលគេបានរកឃើញពពួកជនជាតិសៀម ( les Siamois ) នាពេលថ្មីៗនេះបានតតាំងទប់ទល់នឹងការក្រោកឡើងភ្ញាក់រលឹកឡើងវិញនៃប្រជាជាតិខ្មែរ នៅពេលចូលលុកលុយរាតត្បាតរបស់ខ្លួន បានកាប់សម្លាប់ឬចាប់នាំយកទៅនូវក្រុមខណ្ឌអ្នកដឹកនាំខ្មែរទាំងឡាយ ។

ទោះបីយ៉ាងណាក៏ដោយ កិច្ចការជាបន្ទាន់ កិច្ចការជាចាំបាច់ គឺត្រូវផ្តល់ឲ្យដល់ជនជាតិភាគតិចខ្មែរនៅដែនកូសាំងស៊ីន នូវមធ្យោបាយគ្រប់គ្រាន់សំរាប់ជួយធានាដល់បុគ្គលិកលក្ខណៈជាមនុស្សភាព (les moyens de sauvegarder sa personna lité ) ដោយបង្កបង្កើតជាសាលារៀនសំរាប់ពួកគេ ហើយជាពិសេសទៅទៀតតោងបញ្ឈប់នូវទម្លាប់ដែលបានត្រឹមផ្តល់នូវប្រាក់កាសទ្រព្យបន្តិចបន្តួចចិញ្ចឹមខ្លួនស្ទើរមិនរស់ ដែលរមែងតែងតែផ្តល់ឲ្យដល់គ្រូបង្រៀនខ្មែរនៅតាមភូមិស្រុកទាំងឡាយនូវប្រាក់បៀវត្សរ៍តិចតួចស្តួចស្តើងណាស់ដូចជាក្នុងករណីគ្រូបង្រៀននៅដែនកូសាំងស៊ីននេះស្រាប់ ដែលក្នុងឆ្នាំ១៩៤៣គ្រូៗត្រូវបានជ្រើសរើសបានមកដោយលំបាកតែប្រាក់ខែពួកគេក្នុងការបំពេញសកម្ម- ភាពវិជ្ជាជីវៈ បូកផ្សំនឹងប្រាក់បំណាច់ ( les indemnités comprises) បានត្រឹមតែម្ភៃមួយពីយ៉ាស់ (21 piastres ប្រាក់សម័-នោះ ) ក្នុងមួយខែ ។ បញ្ហាបញ្ចូលការរៀនសូត្រទៅក្នុងសហគមជនជាតិភាគតិចទាំងនោះ មិនមែនជាបញ្ហាតែមួយគត់ដ៏សមរម្យ ដែលគេតម្រូវឲ្យយើង ប្រកបដោយសុឆន្ទៈគ្រប់គ្រាន់ប៉ុណ្ណោះឡើយ តែតោងមានថវិកាបរិបូណ៌ថែមទៅទៀត ។ អ្វីៗសព្វបែបយ៉ាងសុទ្ធតែចេញមកពីអវិជ្ជា ។ ប្រជាកសិករខ្មែរត្រូវមានសិទ្ធិក្នុងការស្វែងរកវិជ្ជា ។ ដោយមានចិត្តស្រឡាញ់យ៉ាងខ្ជាប់ខ្ជួននូវទឹកដីជាកេរ្តិ៍អាករមត៌កពីដូនតារបស់គេរាប់តំណាមកហើយនោះ ម្លោះហើយពួកគេឥតមានទាំងគ្រឿងសព្វាវុធយុទ្ធោបករណ៍អ្វីទាល់តែសោះ សំរាប់ការពារនូវបេតិកភ័ណ្ឌជាតិរបស់ពួកគេផង ( son patrimoine ) ដូច្នោះហើយជារឿយៗ ពួកគេត្រូវទទួលរងគ្រោះដោយការប្រើល្បិចកលដណ្តើមយក ឬដោយការប្រើកម្លាំងបាយ (spoliation)។ ព្រះសង្ឃជាអ្នកឧបត្ថម្ភគាំពារ ជាធម្មតាដល់ពពួកគេអប់រំណែនាំពួកគេឲ្យដើរតាមមាគ៌ាដ៏ល្អប្រពៃតាមផ្នែកសីលធម៌, មនុស្សធម៌, សាមគ្គីធម៌, មិនបៀតបៀនអ្នកដទៃពោលដោយខ្លីគឺថែរក្សាយ៉ាង ម៉ឺងម៉ាត់នូវទំនៀមទំលាប់ប្រពៃណីពីបូរំបូរាណកាល

តែដោយមិនបានគិតទៅ ដល់ពន្លឺនៃអនាគតដ៏រុងរឿងនៃការរស់នៅនាសម័យទំនើបនោះឡើយ ។ ពួកចាស់ព្រឹទ្ធាចារ្យ ដែលពួកគេរមែងតែងតែគោរព និងស្នើរសួរយោបល់ផ្សេងៗនៅពេល ដែលជួបនូវឧបសគ្គដ៏លំបាកម្តងម្កាលនោះ ក៏ពួកចាស់ៗទាំងនោះបានត្រឹមតែអ្នកក្លាហានអង់អាច ប្រកាន់ខ្ជាប់ខ្ជួននូវប្រពៃណីពីបូរាណដែលឥតមានទាំងចារីកអ្វីជាក្បួនខ្នាតសោះឡើយ (ធ្វើតាមតៗគ្នា) ក៏ពួកគេទាំងនោះឥតមានអ្វីជាទីពឹងពំនាក់ផងដែរ ។ នៅចំពោះមុខនៃការចាំបាច់ដែលគ្មានចេះអត់ឱនឬលើកលែង ក្នុងការរៀបចំចាត់ចែងផ្នែកសង្គមកិច្ច ហើយដែលសេចក្តីស្មោះត្រង់របស់អ្នកទន់ខ្សោយ ត្រូវបានគេលើកយកបង្ហាញឲ្យឃើញពីការប្រយុទ្ធយកទីកន្លែង បានប្រព្រឹត្តទៅដោយតឹងតែងបំផុត គួរឲ្យព្រឺ...។

ការប៉ះទង្គិចរវាងជាតិសាសន៍ពីរខុសគ្នា ដែលមួយសកម្មមិនចេះនៅស្ងៀមរបុិលរប៉ូច ដែលក្លាហានមិនញញើតញញើម ហើយដែលមួយទៀតលែងឈឺចាប់ឬខ្វល់ព្រួយ ហើយដែលជាអ្នកប្រពៃណីនិយម រមែងផ្តល់ឲ្យជារឿងរាល់ថ្ងៃ ជាអចិន្ត្រៃយ៍នូវការរំលោភគេងប្រវ័ញ្ច នូវភាពដែលជ្រុលហួសហេតុ ។ តែប្រទេសយើងគ្មានមធ្យោបាយ... មិនដឹងធ្វើយ៉ាងណា ដើម្បីគ្របសង្កត់ឬបង្ក្រាបនូវជម្លោះទាស់ទែងខ្វែងគំនិតគ្នាអស់ទាំងនេះបាន ។ ហើយដែលភារៈកិច្ចនេះត្រូវធ្លាក់ទៅលើនាយកខាងគណបេសកកម្មសហព័ន្ធទទួលបន្ទុកខាងសំរុះសំរួលអធិករ ឬជាអជ្ញាកណ្តាល (Chef de la mission fédérale d'arbitrage) ដែលត្រូវជ្រើសរើសតែង




រូបថតព្រះវិហារវត្តពោធិសាលរាជកំពង់ កសាងមុនឧកញ្ញាសឺង-គុយពលិកម្មជីវិតឆ្នាំ១៨៩១

តាំងឡើងសំរាប់ឥណ្ឌូចិនទាំងមូល ។ ខ្ញុំបានស្គាល់ភូមិករមួយកន្លែងនៅក្នុងខេត្តឡុងស្មៀង ដែលត្រូវគេរំលាយបញ្ចូលគ្នា រវាងភូមិខ្មែរនិងភូមិយួន ។ វិធានការណ៍នេះបានត្រូវចាត់ចែងធ្វើឡើង ដោយអាជ្ញាធរផ្នែករដ្ឋបាល ដោយសំរេចធ្វើគ្មានការប្រុងប្រយ័ត្នប្រយែងអ្វីទាល់តែសោះ ។ លទ្ធផលគឺធ្វើឲ្យខ្មែរអស់កេរ្តិ៍អាកររបស់ខ្លួននៅក្នុងភូមិអស់រលីង ដោយគេយកទៅចែកឲ្យយួនដែលក្រីក្រឥតមានដីធ្លី ជាហេតុធ្វើឲ្យសាលារៀនយួនរីកចំរើនដុះដាលវាលគុម្ព ។ ចំណែកខាងសាលារៀនខ្មែរ ស្ថិតនៅក្នុងរបៀបអន់ខ្សោយតទៅមុខ ដោយហេតុតែគ្មានប្រភពទ្រព្យសម្បត្តិអ្វីផ្តល់ឲ្យ ។ ខ្ញុំគួររៀបរាប់ផងដែរ នូវភូមិខ្មែរមួយក្នុងខេត្តរ៉ាច់យ៉ា ដែលតាំងនៅមិនឆ្ងាយពីផ្លូវគមនាគមន៍និងពីផ្លូវទឹក ។ ថ្ងៃមួយ ប្រជាពលរដ្ឋខ្មែរក្នុងភូមិនោះ ទើបនឹងបានដឹងដោយការងឿងឆ្ងល់យ៉ាងខ្លាំង ដោយស្រទ្បាំងកាំងតាមរយៈខ្ញុំ ថាពួកគេពិតជាមិនមែនជាម្ចាស់នៃកម្មសិទ្ធិដីធ្លីរបស់ផងគេឡើយ សូម្បីតែដីដែលពួកគេបានសង់ទីលំនៅជាស្រេច រួចតាំងពីយូរយារណាស់មកហើយនោះក៏ដោយ ។ ព្រោះថាដីត្រង់កន្លែងនេះ ត្រូវបានគេដាក់បញ្ចូលទៅក្នុងដីកម្មសិទ្ធិសាធារណៈ (Domaine public ) ដោយហេតុតែថា ដីត្រង់កន្លែងនេះឥតបានបង្ហាញ ថាជាដីកម្មសិទ្ធិមានម្ចាស់កាន់កាប់ជាអលជ្ជី ព្រោះគេយល់ថាឥតមាននរណាម្នាក់ ទៅប្តឹងផ្តល់ចំពោះគណៈកម្មការសុរិយោដី (ក្រុមផែនទី ) ក្នុងន័យរៀបចំព្រំប្រទល់ដីឲ្យបានត្រឹមត្រូវ ហើយក៏ព្រោះតែគ្មាននរណាឲ្យដំណឹងពីរឿងនេះ ដល់ពួកគេផងដែរ ។

តើគួរឲ្យងឿងឆ្ងល់ផងដែរឬទេ ? បើសិននៅចំពោះព្រឹត្តិហេតុ ដែលគេចាត់ទុកជាវិធានការណ៍បណ្តោះអាសន្ននេះ ប្រជាជនខ្មែរទាំងហ្វូងទាំងហ្វាយ ជួនកាលទាំងភូមិតែម្តងបានរត់បោះបង់ចាកចោលលំនៅដ្ឋានរបស់ពួកគេ ព្រោះតែចង់គេចចេញផុតពីអំពើអយុត្តិធម៌ និងពីការដណ្តើមយកដោយប្រើល្បិចកល ឬដោយប្រើកម្លាំងប្រវ័ញ្ចយក ( pour fuir l'Injustice et la spoliation ) ពពួកម្ចាស់បំណុល ( Des créanciers annamites ou chinois ) យួនឬចិនរមែងឲ្យកសិករខ្មែរ ដែលមិនចេះអក្សរស៊ីញ៉េលើលិខិតបញ្ជាក់ឆរបោក ឃើញក្នុងរយៈពេលយ៉ាងខ្លីខាងមុខ អ្នកជំពាក់បំណុលគេ ( le débiteur ) រកប្រាក់សងគេមិនបាន ក៏ត្រូវគេអូសយកកេរ្តិ៍អាករអស់រលីង ។ ការខូចខាតបាត់បង់អន្តរាយ បានបង្ហាញឲ្យឃើញយ៉ាងជាក់ច្បាស់ណាស់ ហើយការយកការប្រាក់ហួសកំណត់ ខុសច្បាប់ ការទាញយកផលកំរៃហួសហេតុ បានក្លាយទៅជាទម្លាប់ធម្មតាទៅហើយ ដូចជាការដកយកកម្មសិទ្ធិដីធ្លី ( ពីអ្នកខ្ចីប្រាក់) ដោយខុសច្បាប់យ៉ាងនេះ គួរណាស់តែផ្នែករដ្ឋបាលបារាំង ធ្វើឲ្យភ្ញាក់ផ្អើលអំពីរឿងនេះឡើង ។ ក្នុងឆ្នាំ១៩៣៧ ទិដ្ឋាការ – ការកត់ឬចុះបញ្ជីត្រូវបានប្រកាសឲ្យធ្វើជាចាំបាច់ដោយខានពុំបាន នៅលើលិខិតជំពាក់បំណុល ដោយមានការចុះហត្ថ

លេខារួមគ្នា រវាងអ្នកខ្ចី ( débiteur ) និងម្ចាស់បំណុល ( créancier ) ។ នៅខេត្តត្រាវិញ គេបានឃើញថា ជាចាំបាច់តោងសាមីជន ( អ្នកខ្ចីនិងម្ចាស់បំណុល ) មកបង្ហាញខ្លួនដោយផ្ទាល់ នៅពេលចុះក្នុងបញ្ជី ពីសិទ្ធិអំណាចនៃអ្នកម្ចាស់បំណុលដែលអាចកាន់កាប់របស់ដែលគេបញ្ចាំឲ្យ ( hypothèque ) ក្នុងបញ្ជីនៃកម្មសិទ្ធិដៃធ្លី ។

ម៉្យាងវិញទៀត យើងមានបំណងសុំឲ្យមានការពង្រីកពង្រឹងនូវវិធានការណ៍ខ្លះដែលបានសំរេចអនុម័តរួចហើយ នៅពេលមុនសង្គ្រាម ដោយអាជ្ញាធរបារាំង ។ ជាពិសេសវិធានការណ៍ ដែលបានគូសបញ្ជាក់ថា នៅតាមភូមិករទាំងឡាយណាដែលរួមចំរុះគ្នា តោងឲ្យមានអ្នកធំជុំ អ្នកមុខអ្នកការខ្មែរ ( les notables ) ស្របបុសមាមាត្រទៅនឹងចំនួនប្រជាពលរដ្ឋរួមឈាមរបស់ខ្លួន ឬជាបន្ថែមពីលើនេះទៅទៀត តោងមានមន្ត្រីជំនួយខ្មែរម្នាក់ ក្នុងបញ្ជាអាត្រានុកូលដ្ឋាន ( Un officier auxiliaire khmer d'Etat Civil ) នៅតាមភូមិទាំងឡាយណា ដែលមានជនជាតិខ្មែរភាគច្រើនរស់នៅ ។ តែវិធានការណ៍ទាំងនោះ នឹងអាចក្លាយទៅជាមានប្រសិទ្ធិភាពពេញបរិបូណ៌ទៅបាន ក៏អាស្រ័យទៅលើអ្នកមុខអ្នកការ ដែលបានត្រូវគេចាត់តាំងទាំងនោះមានមុខងារជាន់ថ្នាក់ជាលំដាប់លំដោយ និងដោយយោលទៅលើករណីខ្លះៗ ព្រមទាំងយោងទៅលើចំនួនដ៏សំខាន់នៃជនជាតិភាគតិច ហើយអ្នកមុខអ្នកការ ឬតំណាងទាំងនោះតោងមានមុខនាទីយ៉ាងសំខាន់ ក្នុងបណ្តាសមាជិកនៃក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ជាការសំខាន់ណាស់ទៅទៀត តោងអ្នកតំណាងរបស់ខ្មែរទាំងនោះ ត្រូវមានមុខនាទីដែលបានមកជារបស់ផងខ្លួន ទោះបីនៅក្នុងអង្គភាពណាក៏ដោយ ទោះបីក្នុងលំដាប់ជាន់ថ្នាក់ណាក៏ដោយ ។ ប្រហែលជាងម្ភៃឆ្នាំប្លាយមកហើយ គេបានស្នើថា នៅក្នុងស្រុកណាដែលជាតំបន់ស្វយ័ត ស្រុកនោះឯងតោងទាក់ទងដោយផ្ទាល់ទៅអាជ្ញាធរជាន់ខ្ពស់ ។ តើកិច្ចការនេះនឹងធ្វើទៅកើត ទាល់តែមានជនជាតិភាគតិច មានវត្តមានច្រើនគ្រប់គ្រាន់ ឲ្យសមស្របទៅតាមវិធានការណ៍នេះឬ (??) ។ គេអាចចាប់ផ្តើមធ្វើការតែងតាំង «មេស្រុក» ( ចៅហ្វាយស្រុកឬអភិបាលស្រុក ) មានសញ្ជាតិជាខ្មែរ ដោយត្រូវប្រកាសជ្រើសរើសតែងតាំងជាផ្លូវការជាចាំបាច់ នៅក្នុងតំបន់ណាៗ ដែលមានប្រជាជនភាគតិចខ្មែររស់នៅច្រើនណាស់ណាពេកទេ ។ ទោះបីយ៉ាងណាក៏ដោយ នៅគ្រប់លក្ខណ:ទាំងអស់ ខ្មែរតោងមានមុខនាទីនៅក្នុងផ្នែករដ្ឋបាល ឬក្នុងក្រុមប្រឹក្សានានា ដោយនិយាយភាសាជាតិរបស់ខ្លួន ។ នៅក្នុងការប្រឡងប្រជែងជ្រើសរើសមន្ត្រីរដ្ឋបាលទៀតសោត ចំនួនកន្លែងត្រូវតែរក្សាទុកសំរាប់បេក្ខជនមានសញ្ជាតិជាខ្មែរ ក្នុងការជ្រើសរើសកន្លែងធ្វើការក្នុងមុខងារសាធារណ: ឬដោយមានមុខងារជាបណ្តោះអាសន្នសិនចំពោះករណីណាពិសេសៗ ។ ទង្វើបែបនេះ ជាហេតុញ៉ាំងឲ្យភាសាខ្មែរហាក់បីដូចជាមានប្រយោជន៍ ជាផ្លូវការដែរ ។ ដូច




រូបថតចេតិយវត្តព្រៃកស្លា កំពុងកសាងឡើងវិញបន្ទាប់ពីសង្គ្រាមយៀកណាម
បានរលត់៣០មេសា១៩៧៥ ។ វត្តព្រៃកស្លា ភូមិព្រៃកស្លា ខេត្តក្រមួនស ។

ជាការរ៉ាយរ៉ាប់ក្នុងពាក្យបណ្ដឹង-ក្ដីតវ៉ាអ្វីផ្សេងៗ ឬលិខិតទាក់ទងក្នុងផ្នែករដ្ឋបាល ។ ជាទីបញ្ចប់គេអាចសុំឲ្យមានកាន់តែច្រើនឡើង នូវការិយាល័យ, មន្ទីរនានា សំរាប់កិច្ចការរបស់ខ្មែរ ដែលគេបានបង្កបង្កើតខ្លះរួចមកហើយ នាពេលមុនសង្គ្រាមនៅអមខុទ្ទកាល័យនៃទេសាភិបាល ។

★ នៅដែនកូសាំងស៊ីន ប្រជាពលរដ្ឋខ្មែរមានចំនួនក្រាស់ក្រែលសំខាន់ណាស់ ចំនួននេះឥតមានថយក្រោយ មានតែពីកើនទៅមុខជាដរាប នៅរាល់ពេលណាដែលគេធ្វើការជំរឿនប្រជាជនម្ដងៗ ។ ក្នុងឆ្នាំ១៨៨៨ ខ្មែរកូសាំងស៊ីនមានចំនួន១៥០,០០០នាក់ ក្នុងចំណោមប្រជាជនសរុប ១,៦០០,០០០នាក់ ។ ក្នុងឆ្នាំ១៩២៥ ពលរដ្ឋខ្មែរនៅដែនកូសាំងស៊ីនបានកើនឡើងរហូតដល់ទៅ ៣០០,០០០នាក់ ។ នៅមុនសង្គ្រាមផ្ទុះឡើង គេរាប់ឃើញមានចំនួនប្រមាណ ៣៥០,០០០នាក់ ក្នុងបណ្ដាជនសរុបដែលមានតិចជាង៥លាននាក់ ។ ទំនាក់ទំនងរបស់ពួកគេជាមួយជនជាតិចិន មានភាពល្អប្រសើរណាស់ ហើយគេសង្កេតឃើញមាន កូនកាត់ខ្មែរ-ចិន ( de nombreux métis sino-cambogiens ) ដែលព្រឹត្តិការណ៍ដ៏ចម្លែកមួយគួរកត់សម្គាល់ គឺគេគោរពដោយស្មោះស្ម័គ្រ ទៅតាមប្រពៃណីទំនៀមទំលាប់តាមខាងម្ដាយ ហើយដែលជាការកំរមានករណីបែបនេះណាស់ ចំពោះកូនកាត់ចិន-យួន ( les métis sino-annamites ) ។ ជាទូទៅ ខ្មែរនៅដែនកូសាំងស៊ីនមានទំនាក់ទំនងជាមួយយួន ដោយឥតមានការស្រឡាញ់ចូលចិត្តទាល់តែសោះ ( des relations dénuées de sympathie ) ។

( កំណត់អ្នកបកប្រែ ៖ រឿងនេះជាការពិតឥតប្រកែកបាន មានខ្ញុំជាសាក្សី ។ នៅភូមិខ្ញុំ មានគ្រួសារចិនមួយឈ្មោះចឹកកង គាត់អញ្ជើញមកពីស្រុកចិនតាំងពីតូច មករស់នៅក្នុងភូមិខ្មែរ ទទួលអរិយធម៌-ប្រពៃណីខ្មែរ ។ គាត់រកស៊ីខ្វៃនិងកាប់ជ្រូកលក់ ពេលខ្មែរធ្វើបុណ្យទានម្ដងៗ ។ គាត់មានកូនប្រុស៥នាក់ កូនស្រី២នាក់ ។ កូនប្រុសទាំង៥នាក់បួសរៀននៅវត្តខ្ញុំ ។ កូនច្បងបួសរហូតដល់ឡើងជាគ្រូចៅអធិការវត្តខ្ញុំ គឺជាគ្រូខ្ញុំទី១ ដែលបានបើកប្រស្រីភ្នែកខ្ញុំឲ្យចេះអក្សរខ្មែរ ។ ឯកូនប្រុសបន្ទាប់ ឡើងជាគ្រូសូត្រស្ដាំ ។ ដល់សឹកមក ( ចាក់សិក្ខាបទ ) រៀបការប្រពន្ធជាកូនពូខ្ញុំ ៖ សែខ្មុតដូចខ្ញុំ ។ ចិនរស់នៅយ៉ាងសុខដមរមនា ក្នុងសង្គមខ្មែរដូចបងប្អូនបង្កើត ។ ឯយួននិងខ្មែរដូចទឹកនឹងព្រេង ។ សម័យដើមជំនាន់មុនៗខ្ញុំ ឬជំនាន់ខ្ញុំនេះ បើប្រុសណាហើយទៅយកប្រពន្ធយួន អ្នកស្រុកគេមិនសូវរាប់អាននិយាយរកទេ ។ ក្នុងសាលារៀនពេលចេញលេង, ពេលចេញទៅផ្ទះ  កូនខ្មែរ-កូនយួនវាយគ្នាពកមុខបែកមាត់អស់ហើយ ) ។

តាមចំណាងចិត្តរបស់គេ យួន គេហៅខ្មែរថា ៖ « ថៅ » ( Thô = les hommes de la terre  ដូចពួកសំរែ, ពួកល្ងង់ខ្លៅ ។ ក៏ប៉ុន្តែការប្រមាថមើលងាយមើលថោកកើ

តមានទៅវិញទៅមក ។ ខ្មែរហៅយួនថា « យួន Yun » du sanskrit yavana c'est-à-dire les barbares du Nord ពួកសាហាវយង់ឃ្នងមកពីទិសខាងជើង– ពួកអមនុស្សធម៌ ។ ជាការពិតណាស់ពេកទៅហើយថា ភាពមិនត្រូវរ៉ូវ មិនចុះសំរុងគ្នា មិនស៊ីសង្វាក់គ្នា ផ្ទុយគ្នាស្រឡះរវាងទំនៀមទំលាប់ប្រពៃណី, ភាសា, សាសនា រួចថែមទាំងមានភាពល្វីងជូរចត់, ការតូចចិត្តព្រោះដោយហេតុតែការបាត់បង់ដីធ្លី កេរ្តិ៍អាករ ។ល។ ហេតុទាំងអស់នេះហើយ ដែលបណ្តាលឲ្យមានការទាស់ទែងខ្វែងគំនិតគ្នា, ការប៉ះទង្គិចគ្នា, ចងជាគំនុំគុំគួនឥតស្រាកស្រាន្ត... ដែលមានលក្ខណៈមិនច្បាស់ ( une friction latente ) ហើយដែលញ៉ាំងឲ្យខូចខាតដល់សន្តិភាពក្នុងសង្គម ដូច្នេះតោងទាមទារឲ្យមានការត្រួតត្រាមួយមានលក្ខណៈជាអាជ្ញាកណ្តាល ( et qui réclame le contrôle d'un arbitre ) ។

អាស្រ័យហេតុនោះហើយ ដែនដីកូសាំងស៊ីនលេចធ្លោឡើងយ៉ាងច្បាស់ប្រាកដថា ជាទឹកដីសហព័ន្ធដែលបារាំងរមែងមានសេចក្តីអាណិតអាសូរដល់អ្នកទន់ខ្សោយ ហើយមានភាពថ្លៃថ្នូរចំពោះប្រជាពលរដ្ឋដ៏សុចរិតទៀងត្រង់នោះ តោងធ្វើឲ្យមានប្រៀបជាងគេ ក្នុងកិច្ចស្វែងរកដំណោះស្រាយដោយយុត្តិធម៌ និងធ្វើឲ្យមានលំនឹងពេញបរិបូណ៌ជាងការបែកបាក់ នាំឲ្យពិភពលោករលត់រលាយ ដែលជាការប៉ុនប៉ងរបស់អ្នកខ្លាំងនោះឲ្យសោះ ។ ដូច្នេះដើម្បីផ្តល់ឲ្យដល់ជនជាតិភាគតិចខ្មែរនៅភូមិភាគទន្លេមេគង្គភាគខាងក្រោម ( du Bas-Mékong ) នូវលក្ខន្តិកៈនយោបាយ ( un statut politique ) មួយ ដែលរហូតមកដល់ពេលនេះ មិនដែលបានចែងឲ្យច្បាស់ប្រាកដនៅឡើយទេ ។ លក្ខន្តិកៈនោះឯងត្រូវស្រោចស្រង់ដល់សិទ្ធិរបស់ពួកគេតាមវិធានការរដ្ឋបាល – រក្សាទុកឲ្យនៅដដែលក្នុងភាពដើម នូវសម្បត្តិវប្បធម៌របស់ពួកគេ – ការពារជាពិសេសនូវទ្រព្យសម្បត្តិអចលនៈវត្ថុ, បេតិកភ័ណ្ឌ ( កេរ្តិ៍ដំណែលពីឪពុកម្តាយ ) របស់ពួកគេ ដែលកាន់តែថយចុះតិចទៅៗ បន្តិចម្តងៗជារៀងរាល់ថ្ងៃ ដោយសារតែភាពជ្រុលហួស – ភាពអយុត្តិធម៌ – ការរំលោភបោកបញ្ឆោត – ការបំពានកេងប្រវ័ញ្ចយក ដែលជាការមិនអាចជឿបាន ។ ខ្ញុំត្រូវតែនិយាយបន្ថែមទៀត ខ្ញុំត្រូវតែនិយាយបន្ថែមទៀតថា ប្រទេសបារាំងរបស់យើង មិនត្រឹមតែមិនរវល់ពីបញ្ហានេះប៉ុណ្ណោះទេ តែតោងផ្តល់នូវគុណភាពដ៏ចំបងឲ្យដល់ប្រជាពលរដ្ឋទាំងនោះទៀតផង ។ ជនភាគតិចខ្មែរនៅដែនកូសាំងស៊ីន រមែងមានការជាប់ជំពាក់ទៅលើជំនឿខាងពុទ្ធសាសនាប៉ែកខាងត្បូង ( ហិនយាន ) តាំងពីបូរំបូរាណកាលតរៀងមកម្ល៉េះ ។ ចំណែកខាងនគរអាណ្ណាមវិញ ទទួលរើសយកពុទ្ធសាសនាបែបបទភាគខាងជើង ( មហាយាន ) ។ ដូច្នេះវាជាភារៈរបស់ប្រទេសបារាំង ដែលជាប្រជាជាតិមួយប្រកាន់យកសាសនាគ្រីស្ទ និងជាប្រជាជាតិសេរីជាយូរអង្វែងមកហើយនោះ តោង




រូបថតខាងលើ ៖ « សមាគមខ្មែរកម្ពុជាក្រោម » កសាងឡើងក្នុងឆ្នាំ១៩៣៣ ។ ក្រោយឆ្នាំ១៩៧៥ យួនបានកែប្រែឈ្មោះសមាគម នេះ ដោយដាក់ថា « ចំណងមិត្តភាពខ្មែរវៀតជាអមតៈ » វិញ ។ សមាគមនេះស្ថិតនៅក្នុងហូវយ៉ាង ។

ខិតខំធ្វើយ៉ាងណាឲ្យភូមិភាគអាស៊ីប៉ែកអគ្នេយ៍ ក្លាយទៅជាមជ្ឈមណ្ឌលមួយប្រកាន់យកព្រះពុទ្ធសាសនាតែមួយបែបគត់ ដូចដែលប្រទេសបារាំងបានខិតខំធ្វើឲ្យទ្វីបអាហ្វ្រិកក្លាយជាមណ្ឌលសាសនាឥស្លាមអីចឹងដែរ ។ មិនមែននិយាយដោយការលាក់លៀមអ្វីឡើយ ដែលថាប្រទេសជប៉ុនបំរុងនឹងចាត់ចែងបែបនេះដែរ ដើម្បីជាប្រយោជន៍ដល់ខ្លួន ពោលគឺបង្រួមនិកាយព្រះពុទ្ធសាសនាទាំងអស់នៅលើដែនដីឥណ្ឌូចិនទាំងមូល ហើយប្រទេសសៀមក៏បានបន្តនូវកិច្ចការនេះជាយូរយារណាស់មកហើយដែរនៅប្រទេសកម្ពុជា ក្នុងគោលបំណងដូចគ្នា ដើម្បីឆ្លៀតឈ្លានពានប្រវ័ញ្ចពង្រីកយកទឹកដី ។ ព្រះសង្ឃខ្មែរនៅដែនកូសាំងស៊ីន មានភារៈផ្សព្វផ្សាយព្រះពុទ្ធសាសនា តាមរយៈវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិតស្ថិតនៅទីក្រុងភ្នំពេញ ( Institut Bouddhique de Phnom Penh ) ហើយដែលមានទំនាក់ទំនងទៅនឹងប្រទេសលាវ

ផងដែរ ។ វិជ្ជាស្ថានមានលក្ខណៈជាសហព័ន្ធដោយមានសមណរួមពរចង់ឲ្យមានការលូតលាស់ល្អប្រសើរ ហើយសារៈប្រយោជន៍ក៏មិនមែនជាការអស់សង្ឃឹមនោះដែរ

ខ្ញុំចង់បញ្ជាក់បន្ថែមនៅទីបញ្ចប់នេះ ដើម្បីទាក់ទាញអារម្មណ៍ដល់អស់លោក-អ្នកនូវទង្វើខ្លះៗដែលត្រូវប្រព្រឹត្តចំពោះប្រជាពលរដ្ឋទាំងនោះ នៅពេលណាដែលពួកគេ សុំអញ្ជើញអស់លោកអ្នកទៅធ្វើទស្សនកិច្ចតាមភូមិស្ថានរបស់ពួកគេម្តងម្កាល ។ ជាការល្អ ពេលណាគេចូលទៅក្នុងបរិវេណវត្តអារាមណាមួយហើយ តែងតែមានព្រះសង្ឃជាភិក្ខុឬលោកនេននិមន្តមកទទួលលោកអ្នក តាំងពីខ្លោងទ្វារចូលជានិច្ច ។ លោកអ្នកទូលលោកថា លោកអ្នកចង់ស្នើទៅថ្វាយបង្គំព្រះគ្រូចៅអធិការ ដែលជាព្រឹទ្ធាចារ្យគួរជាទីគោរពរបស់អ្នកភូមិស្រុក ។ បើសិនជាចំពេលលោកឆាន់ ឬចំពេលលោកសឹង ( សំរាក ) ដើម្បីជាការគួរសម មិនគួរទទូចដោយចចេសចង់បានជួបភ្លាមៗនោះឡើយ ។ ជនជាតិខ្មែរតែងមានការចាប់អារម្មណ៍យ៉ាងខ្លាំង នូវទង្វើអ្វីៗទាក់ទងដល់វត្តអារាមរបស់ពួកគេ ។ បើសិនជាគេជូនទឹកតែឬទឹកដូងដល់លោកអ្នក សុំទទួលយកភ្លាមដោយរីករាយទៅ បើទុកជាកែវឬពែងមានជាប់ជាតិក្អែលខ្លះៗ ឬបើទោះបីលោកអ្នកមិនស្រេកក៏ដោយ ព្រោះថាអំណោយឬជំនូនទាំងនោះ បានផុះចេញពីបេះដូងឬទឹកចិត្តដ៏បរិសុទ្ធរបស់ពួកគេតែម្តង ដោយចិត្តទូលំទូលាយ ។ ចូរអ្នកអង្គុយលើកន្ទេលកក់ រំលេចពណ៌ដ៏ស្រស់ស្អាត បើប្រសិនជាព្រះគ្រូចៅអធិការអញ្ជើញអ្នក ។ អ្នកឯទៀតៗគេអង្គុយព័ទ្ធជុំវិញអស់លោកជារង្វង់ ហើយគេប្រុងប្រៀបស្តាប់យោបល់លោកអ្នកដោយយកចិត្តទុកដាក់ និងដោយស្ងៀមស្ងាត់គួរជាទីគោរព ។ ចូរលោកអ្នកស៊ើបសួរដំណឹងពីសេចក្តីត្រូវការ, ពីអាគារ ( កុដិលោក, សាលាឆាន់, ព្រះវិហារ, សាលារៀន... ) ពីផលិតផលស្រូវអង្ករ និងដំណាំដាំដុះផ្សេងៗ, ពីសុខភាពឬជម្ងឺដំកាត់ នៃសត្វពាហនៈ ឬសត្វបក្សាបក្សី យកសាច់ធ្វើជាអាហារ ( មាន់ ទា ជ្រូក ), ពីកិច្ចការរៀនសូត្ររបស់សិស្សានុសិស្សកូនចៅជើងវត្ត, ពីស្ថានភាពសាលារៀន ( អាគារ, សម្ភារៈផ្សេងៗ, ចំនួនសិស្សប្រុសស្រី, ចំនួនគ្រូ, ពីសេចក្តីត្រូវការ ។ល។ និង ។ល។ សូម លោកអ្នកកុំភ្លេចឲ្យសោះទៅធ្វើទស្សនកិច្ចដល់សាលារៀនផ្ទាល់តែម្តង - សួរសុខទុក្ខដល់ព្រះសង្ឃជាគ្រូបង្ហាត់បង្ហាញ ។ ចែកស្ករគ្រាប់ឬរូបភាពផ្សេងៗដល់សិស្សប្រុសស្រី ។ ក្នុងការនិយាយស្តី តោងប្រើពាក្យទន់ភ្លន់ចំពោះចាស់ព្រឹទ្ធាចារ្យ - សំដីផ្អែមល្ហែមទាក់ទាញចិត្តឲ្យគេស្រឡាញ់ចូលចិត្ត ។ ក្នុងឱកាសនោះលោកអ្នកបញ្ចេ ញនូវអាកប្បកិរិយារីករាយសប្បាយ ( Soyez jovial à l'occasion ) ។ ខ្ញុំអាចយកពត៌មានដ៏សំខាន់ៗ ដែលដឹកនាំខ្ញុំឲ្យទៅស្រាវជ្រាវរកឃើញនូវកន្លែងកប់វត្ថុបុរា-ណដ៏ល្អៗប្រពៃ ដោយខ្ញុំគ្រាន់តែត្រឹមចែកជូបដល់ពួកគេនូវ ៖ ប្រអប់ឈើគូស, បារី, កញ្ចប់ធូប, ទៀន ឬក៏ដុំសាប៊ូ ឬក៏គ្រាន់តែត្រឹមជួយព្យាបាលរបួសដំបៅបន្តិចបន្តួច

ប៉ុណ្ណោះ ឬម៉្យាងទៀតត្រឹមតែបន្តក់ថ្នាំដាក់ភ្នែកឲ្យដល់កុមារា-កុមារីទាំងឡាយណា ដែលកើតជម្ងឺភ្នែកងារ ( ឈឺភ្នែក-ហើមភ្នែក ) ។ ត្រូវចេះស្ងួរទ្រាំអត់ធ្មត់, មិនត្រូវប្រញាប់ប្រញាល់ពេកទេ ហើយក៏គេមិនដែលប្រគេនបច្ច័យ ( ប្រាក់កាស់ ) ទៅព្រះសង្ឃដោយផ្ទាល់ដៃដែរ ។ វិន័យមិនអនុញ្ញាតឲ្យលោកទទួលយកប្រាក់ពីគ្រហស្ថ ។ តែពេលនោះ បើសិនជាការចាំបាច់ណាស់ ត្រូវអ្នកប្រគេនលោកតាមអាចារ្យវត្ត ឬបុគ្គលចាស់ទំណាម្នាក់គួរជាទីទុកចិត្ត ( par l'intermédiaire d'un laîc, achar ou autre ) ដោយបញ្ជាក់ជានិច្ចថា ៖ ប្រាក់នេះជាវិភាគទានផ្ទាល់ខ្លួនរបស់លោកអ្នក ឬជារបស់រដ្ឋបាល សំរាប់ជាកិច្ចជួយកសាងជួសជុលវត្តអារាម ឬសំរាប់ជួយពង្រីកសាលា រៀន...។

ប្រសិនបើលោកអ្នកត្រូវការស្នាក់នៅមួយរយៈក្នុងវត្ត ឬក៏ត្រឹមតែបោះជំរុំបណ្ដោះអាសន្ន សុំលោកចេញបញ្ជាដល់អ្នកនៅក្រោមបង្គាប់ កុំឲ្យមាត់កឡូឡាខ្លាំង




រូបថតខាងលើ គឺព្រះវិហារវត្ត « សុវណ្ណមាលីព្រះបាង្គ » ដែលទើបធ្វើបុណ្យសម្ពោធថ្មីៗនេះ( កាលពីថ្ងៃទី១-២-៣ ខែមេសា ឆ្នាំ១៩៩៩ )

ប្រសិនបើលោកអ្នកត្រូវការស្នាក់នៅមួយរយៈក្នុងវត្ត ឬក៏ត្រឹមតែបោះជំរុំបណ្តោះអាសន្ន សុំលោកចេញបញ្ជាដល់អ្នកនៅក្រោមបង្គាប់ កុំឲ្យមាត់កឡូឡាខ្លាំងពេក ជាពិសេសពេលព្រះសង្ឃកំពុងសូត្រធម៌ថ្វាយបង្គំព្រះ ឬពេលកំពុងមានពិធីផ្សេងៗ ។ ទោះបីទីធ្លាវត្តទូលំទូលាយយ៉ាងណាក៏ដោយ ជាការប្រសើរគួរបោះជំរំ ឬសាងសង់សំណង់អ្វីៗជាបណ្តោះអាសន្នទាំងនោះ នៅក្រៅបរិវេណវត្ត ដើម្បីជាការសមស្របទៅតាមសេចក្តីត្រូវការនៃជីវិតរស់នៅខាងផ្នែកសម្ភារៈ ។ តោងប្រយ័ត្នប្រយែងជាពិសេស កុំឲ្យមានការសម្លាប់សត្វធាតុទាំងឡាយ ៖ គោ-ជ្រូក ឬមាន់ក៏ដោយ ក្នុងបរិវេណវត្តឲ្យសោះ ។ ព្រោះថាវត្តអារាមជាទីសក្ការៈបូជា ។ ជីវិតសត្វធាតុទាំងអស់មានតម្លៃស្មើគ្នានឹងជីវិតមនុស្សលោកផងដែរ ។ ការប្រុងប្រៀបប្រយ័ត្នប្រយែងទុកជាមុនខ្លះៗទាំងប៉ុន្មាននេះ តាមធម្មតាវាជាការគ្រប់គ្រាន់ណាស់ទៅហើយ សំរាប់ទាក់ទាញប្រជាពលរដ្ឋខ្មែរទាំងឡាយនោះ ឲ្យស្រឡាញ់ចូលចិត្តរាប់អានយើង ព្រោះថាពួកគេសុំតែសេចក្តីស្មោះត្រង់-ទៀងទាត់-ភក្តីភាពពីយើងតែប៉ុណ្ណោះ ។ សេចក្តីកត់សំគាល់ជាច្រើនដូចគ្នានេះដែរ ក៏អាចយកទៅអនុវត្តន៍នៅក្នុងសង្គមយួនបានផងដែរ ។ ហើយត្រូវតែខិតខំសំដែងនូវកម្លាំងចិត្តជានិច្ច ក្នុងការជួយឧបត្ថម្ភ ជួយទំនុកបំរុងជ្រោមជ្រែងដល់ពពួកគេ ដើម្បីជាការទាក់ទាញទឹកចិត្តពួកគេ ឲ្យស្រឡាញ់រាប់អានចំពោះមកយើងវិញ ( pour réussir la conquête de Coeurs ) ។

តាមរយៈនៃសីលធម៌-ទំនៀមទម្លាប់ ឬការរស់នៅដ៏គួរឲ្យកត់សំគាល់យ៉ាងខ្លាំងក្លារបស់ពួកគេ ជនជាតិខ្មែរនៅដែនកូសាំងស៊ីន បានទាក់ទាញទឹកចិត្តយើងឲ្យកោតសរសើរ លើកតម្លៃយ៉ាងខ្លាំងដល់ពពួកគេ ហើយស័ក្តិសមតែបានទទួលនូវការរាប់អានយកចិត្តទុកដាក់ ពីសំណាក់សហគមបារាំងចំពោះពួកគេ ។ ហើយសហគមបារាំងតោងបញ្ចេញបង្ហាញដល់ពពួកជន ដែលរងទុក្ខវេទនា តាមរូបភាព បុគ្គលិកលក្ខណៈជាតិសាសន៍របស់ពួកគេនោះ ឲ្យមានជំនឿជឿជាក់ថា វាសនាអនាគតប្រទេសជាតិផងខ្លួន ដែលគេយកមកនិយាយរៀបរាប់មកបង្កបង្កើតជាថ្មីទាំងអស់គ្នា ឲ្យបានទូលំទូលាយនោះ ព្រោះដើម្បីចៀសវាងជួយសំរាលកុំឲ្យមានការទាស់ទែង ការប៉ះទង្គិចគ្នា ដែលជាហេតុញ៉ាំងឲ្យលេចចេញមកនូវការស្វែងប្រាថ្នារកឧត្តមគតិរួម ។

នាពេលរសៀលថ្ងៃនេះ បានជាខ្ញុំសុខចិត្តយល់ព្រមមកធ្វើការបរិយាយពីជនភាគតិច ក៏ព្រោះតែជនភាគតិចខ្មែរទាំងអស់នោះមានលក្ខណៈថ្លៃថ្នូរ ចង់រក្សាទុកឲ្យនៅដដែល នៃការមិនរំលាយបញ្ចូលគ្នា ដែលគេនិយាយរៀបរាប់មិនកើត ។ គឺជាការពិតប្រាកដណាស់ហើយ ដែលថាខ្ញុំមានវត្តមាននៅទីនេះ ដើម្បីធ្វើជាមេធាវី ឬជាស្មាក្តីតំណាងឲ្យដល់អ្នកទន់ខ្សោយ ។ មិនតែប៉ុណ្ណោះទៀតសោត ក៏ព្រោះតែដែនដីកូសាំងស៊ីននេះជានគរមួយ ពោរពេញទៅដោយប្រវត្តិសាស្ត្រ ដែលជាការត្រឹមត្រូវបំ

ផុតរបស់ជនតំណពូជពង្សអ្នកកសាងប្រាសាទអង្គរយ៉ាងពិតប្រាកដ បន្តការរស់នៅរបស់ខ្លួន ( C'est aussi parce que la Cochinchine est un pays chargé d'histoire où il est juste que survivent les descendants authentiques des batisseurs d'Angkor ) ។ រួចបន្ទាប់មកទៀត សូមអនុញ្ញាតឲ្យខ្ញុំធ្វើការប្តឹងផ្តល់តវ៉ាទៅតុលាការផងដែរ ចំពោះបុព្វហេតុរបស់ពួកគេទាំងឡាយដែលយល់ឃើញថា សកលភាពនិយម ( l'universalisme ) នៅមិនទាន់កើតមានសំរាប់គ្រប់ៗគ្នានៅឡើយទេ ។ អ្វីៗដែលបានធ្វើសំរាប់អ្នកដំណើរ និងសិល្បករ, គ្រឿងប្រទាញចិត្តនិងភាពផ្សេងៗគ្នា- ភាពខុសៗគ្នា- កំពុងត្រូវបានធ្លាក់ហិនហោចលិចលង់ដ៏គួរឲ្យព្រឺខ្លាចទៅក្នុងលក្ខណៈភាពដូចគ្នា នៃរបៀបរស់នៅដូចសព្វដង ។ វាហាក់បីដូចជានៅក្រោមការបង្ខិតបង្ខំដ៏សំបើមគួរឲ្យព្រឺខ្លាចនៃច្បាប់ឧស្សាហកម្មនោះហើយ ដែលញ៉ាំងឲ្យអស់មានមុខនាទីអ្វីសំរាប់ទំនៀមទំលាប់ប្រពៃណីពីដើមដំបូង ដ៏ល្អស្រស់ប្រិមប្រិយគួរឲ្យត្រេក ហើយដែលប្រជាពលរដ្ឋជំនាន់ដើមបានសំដែងបង្ហាញនូវអនុភាពខាងសិល្បៈ ឬទេពកោសល្យរបស់ខ្លួន ។ ក៏ប៉ុន្តែប្រទេសបារាំង ជាប្រជាជាតិមួយដ៏ចាស់បូរំបូរាណ ប្រកបដោយលំនឹងនិងគុណសម្បត្តិក្នុងការវិនិច្ឆ័យ ( La France est une vieille Nation d'équilibre et de raison ) គំនិតត្រិះរិះពិចារណាដ៏ចាស់ទុំដោយការត្រិះរិះល្អិតល្អន់ភ្លឺស្វាងអស់រយៈពេលច្រើនសតវត្សមកហើយរបស់ខ្លួន ( របស់ប្រទេសបារាំង ) តោងពឹងពាក់ទៅលើភាពលាតសន្ធឹង ដែលពោរពេញទៅដោយភាពស្រដៀងគ្នា, ភាពខុសគ្នាតែបន្តិចបន្តួច និងផ្តល់នូវរបៀបរបបលក្ខណៈ ឬទម្រង់ដល់សង្គមណាមួយ ហើយដែលធម្មជាតិនៃមនុស្សលោកបានបញ្ចេញឲ្យឃើញ នូវភាពស្មុគស្មាញទាំងអម្បាលមាណ ។ ចំពោះមតិ, ទស្សនៈ ឬការយល់ឃើញដ៏ងាយជ្រួល និងមិនជាក់ច្បាស់, ត្រឡប់ត្រឡិននៃអ្នកដែលចូលមកដោយយឺតយ៉ាវក្នុងមាគ៌ានៃអារ្យធម៌ ប្រទេសបារាំងមិនត្រូវឈប់ប្រឆាំងជំទាស់ ដោយស្មារតីនឹងនរ ដោយការជំនះចិត្តបាន ដោយគ្មានស្ទើបរំភើបតទៅទៀតឡើយ ចំពោះសញ្ញាណនៃគោលសេចក្តី, ចំពោះភាពប្លែកៗ, ភាពផ្សេងៗពីអ្វីៗដែលមានមែនទែន, ដែលមានពិតប្រាកដ ។ តោងត្រូវតែធ្វើឲ្យកើតមានឡើង, នាពិភពលោកសម័យថ្មីនេះ នូវការវិវត្តន៍នៃគំនិតប្រាជ្ញាស្មារតីថ្មី ដែលមិនមែនមានមូលដ្ឋានចេញពីការងាយស្រួលស្មើៗគ្នានោះទេ តែនៅលើការវិនិច្ឆ័យ ការពិចារណាយ៉ាងហ្មត់ចត់ទៅលើគតិយុត្តិធម៌, ទៅលើច្បាប់ជាធរមាន ដោយធ្វើឲ្យសមស្របនិងទៅលើសិទ្ធិ ( le droit ) របស់គ្រប់ប្រជាជាតិទាំងអស់ ដែលមានវត្តមានរហូតមកដល់សព្វថ្ងៃនេះ ។ សេចក្តីសង្ឃឹមពីរប្រការ ដែលនាំឲ្យយើងមានមោទនភាពសប្បាយរីករាយពេញចិត្តនោះ គឺការទទួលស្គាល់ និងការគោរព ចំពោះការទាមទារដ៏មានប្រយោជន៍សំរាប់មនុស្សជាតិទាំង

មូល ( la double espoir dans lequel il nous plaît de reconnaître et de saluer une revendication d'humanité ) ។៙

ដោយ ល្វី-ម៉ាឡ្សែរ
par Louis Malleret




រូបថតខាងលើ គឺព្រះវិហារវត្ត « អង្គរាជបូរី » ហៅវត្តអង្គរ

★ វិយោគកថារបស់លោកអេង-សារី ៖

ខ្ញុំសូមលំឱនកាយ ដោយគោរពដ៏ខ្ពង់ខ្ពស់ ដល់វិញ្ញាណក្ខ័ន្ធ លោកល្វី-ម៉ាឡ្សែរ ដែលបានផ្ដល់យិត្តិធម៌ដល់សង្គមជាតិរបស់ខ្ញុំ - ដល់មាតុភូមិកំណើតដ៏អភ័ព្វរបស់ខ្ញុំ ។ សូមឲ្យគោលបំណងប៉ុនប៉ងទាំងប៉ុន្មាន ដែលលោកបានស្នើឡើង បានសំរេចប្រការ នាដើមសតវត្សទី២១នេះ ដែលប្រទេសតូចតាចទាំងឡាយក្នុងសកលោក គេរកឃើញឡើងវិញ នូវឯករាជភាព, អធិបតេយ្យភាព និងបូរណភាពទឹកដី... នៅសល់តែខ្មែរកូសាំងស៊ីនប៉ុណ្ណោះ ។៙